ផេង-ព្រឹម

(អតីតសិក្សាធារី នៃអនុវិទ្យាល័យនារីភ្នំពេញ)

# និទានសន្និបាត

សៀវភៅអានភាសាខ្មែរ សម្រាប់ថ្នាក់ទី ៦ នឹងទី ៥ ទំនើប

បោះពុម្ពលើកដំបូង

រក្សាសិទ្ធិ

ព.ស. ២៥០៦ គ.ស. ១៩៦៣

ARCHIVES NATIONALES
REGIE DU DEPOT LEGAL

ផេង-ទ្រឹប

(សញ្ញាប័ត្រសាលាបាលីជាន់ខ្ពស់ភ្នំពេញ)
(ប្រកាសនីយប័ត្រគរុកោសល្យសម្ប៉ុ)
(អតីតសិក្សានារី នៃអនុវិទ្យាល័យនារីភ្នំពេញ)

សេចក្តីកែតម្រូវ

---

អតីតសិក្សានារី អានថាអតីតសិក្សាធារី

ARCHIVES NATIONALES
COTE B.123-1501 37

# និធានសន្និបាត

## សៀវភៅអានភាសាខ្មែរ
## សម្រាប់ថ្នាក់ទី ៦ នឹងទី ៥ ទំនើប

បោះពុម្ពលើកដំបូង

រក្សាសិទ្ធិ

# ប្រកាសក្រសួង

លេខ ២៤២២
ចុះថ្ងៃទី ១៧-៧-៦៦

## រដ្ឋមន្ត្រីក្រសួងអប់រំជាតិនិងវិចិត្រសិល្បៈ

បានឃើញរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រ ។

បានឃើញព្រះរាជក្រឹត្យលេខ ៨-បរ ចុះថ្ងៃទី ២៨ មករា ១៩៦១ ស្ដីអំពីការតែងតាំងគណៈរដ្ឋមន្ត្រី កែប្រែតាមព្រះរាជក្រឹត្យលេខ ៤៩-បរ ចុះថ្ងៃទី ១១ ខែមីនា ១៩៦១ និងលេខ ៥៦៥-បរ ចុះថ្ងៃទី ១៧ វិច្ឆិកា ១៩៦១ ស្ដីអំពីការកែប្រែសមាសភាពនៃគណៈរដ្ឋមន្ត្រីនេះ ។

បានឃើញប្រកាសក្រសួងលេខ ៣៥៧៥ ចុះថ្ងៃទី ២៣.១០-៥៩ ស្ដីអំពីការតែងតាំងគណៈកម្មការសិក្សាធិការជាតិ (ផ្នែករងទី ៣ សម្រាប់មធ្យមសិក្សា) ។

បានឃើញសេចក្ដីកត់ហេតុ ចុះថ្ងៃទី ១១ មេសា ឆ្នាំ ១៩៦៦ របស់គណៈកម្មការសិក្សាធិការជាតិ (ផ្នែករងទី ៣ សម្រាប់មធ្យមសិក្សា) ។

តាមសេចក្ដីស្នើនៃអគ្គនាយកនៃការអប់រំ ។

### សម្រេចៈ

**ប្រការ ១–** សៀវភៅដែលមានចំណងជើង «និទានសន្និបាត» សម្រាប់ថ្នាក់ទី ៦ និងទី ៥ ទំនើប ដែលរៀបរៀងដោយលោក ផេង-ជ្រើ បានបញ្ចូលទៅក្នុងពួកសៀវភៅសិក្សា និងការផ្សាយខាងផ្នែកសិក្សា ដែលអនុញ្ញាតឲ្យប្រើប្រាស់គ្រប់សាលារៀនសាធារណៈក្នុងព្រះរាជាណាចក្រ ។

**ប្រការ ២–** នាយខុទ្ទកាល័យ និងអគ្គនាយកនៃការអប់រំ ត្រូវទទួលភារៈចាត់ការមុខក្រសួងរៀងខ្លួន ដើម្បីឲ្យបានសម្រេចតាមប្រកាសក្រសួងនេះ ។

ភ្នំពេញនៅថ្ងៃទី ១៧ ខែកក្កដា ១៩៦៦

ហត្ថលេខាៈ **ជា-ជិនគុក**

អ្នកទទួលៈ
- មន្ទីរព្រះរាជាយុត្តៈ
- មន្ទីរស្ដីការនាយករដ្ឋមន្ត្រី
- មន្ទីរលេខាធិការដ្ឋាន គណៈរដ្ឋមន្ត្រី–មន្ទីររាជកិច្ច
- រដ្ឋសភាជាតិ–ក្រុមប្រឹក្សាព្រះរាជាណាចក្រ
- គ្រប់វិទ្យាល័យ និង អនុវិទ្យាល័យសាធារណៈ ក្នុងព្រះរាជាណាចក្រ
- សាមីខ្លួន ។
- ក្រសួងអប់រំជាតិៈ ខុទ្ទកាល័យ-អនអ-នយក-កប-ក្រសួងគរុកោសល្យ-អន-មស
- ទីទុកឯកសារ ។

ជាទបមូលដើម្បីចែក

គ- អគ្គលេខាធិការនៃគណៈរដ្ឋមន្ត្រី–គប

ហត្ថលេខា : **ចាន់-គន**

ជាទបមូលត្រឹមត្រូវតាមដើម

អគ្គនាយកនៃការអប់រំ

**ពុង.ប៉េង ចេង**

nº-2422
du 17-7-62

# PRAKAS

LE MINISTRE DE L'EDUCATION NATIONALE ET DES BEAUX-ARTS

Vu la Constitution du Royaume;

Vu le Kret Nº-8-CE du 28 Janvier 1961, portant nomination du Cabinet Ministériel, modifié par les Krets Nº-49-CE du 11 Mars 1961 et Nº-565-CE du 17 Novembre 1961, portant remaniement dudit Cabinet;

Vu le Prâkas Nº-3575 du 23-10-59, portant nomination de la Commission pour l'Enseignement (3ème sous-section pour l'Enseignement Secondaire Nationale);

Vu le Procès-verbal en date du 11 Avril 1962 de la Commission pour l'Enseignement (3ème sous-section pour l'Enseignement Secondaire National);

Sur la proposition du Directeur Général de l'Education.

# ARRETE

*ARTICLE 1er.*— Le manuel ayant pour titre "NITEAN SANIBAT" (recueil de textes pour les classes de 6ème et de 5ème, présenté par M. PHENG CHRIV, est ajouté à la liste des manuels et publications scolaires dont l'usage est autorisé dans toutes les écoles publiques du Royaume.

*ARTICLE 2.*— Le Chef de Cabinet et le Directeur Général de l'Education sont chargés, chacun en ce qui le concerne de l'exécution du présent Prâkas.

Phnom-Penh, le 17 Juillet 1962

*signé :* CHEA CHINKOC

POUR AMPLIATION
P. LE SECRETAIRE GENERAL DU
CONSEIL DES MINISTRES & P.O.

*signé :* CHAN KAN

POUR COPIE CONFORME
LE DIRECTEUR GENERAL DE L'EDUCATION,

PUNG PENG CHENG

# អំណរគុណ

លុះ «និទានសន្និបាត» រៀបរៀងកើតបានជារូបរាងពិតប្រាកដហើយ នៅថ្ងៃទី ៤ ខែវិច្ឆិកា ១៩៥៨ ខ្ញុំបានយកសៀវភៅអាននេះទៅជូនក្រសួងអប់រំជាតិ សូមមេត្តាប្រគល់ជូនទៅគណៈកម្មការពិនិត្យសៀវភៅសិក្សាផ្នែកមធ្យមភូមិ សូមឲ្យគណៈកម្មការមេត្តាសង្គ្រោះជួយពិនិត្យ តើនិទានសន្និបាតនឹងមានសភាពត្រឹមត្រូវនឹងសមរម្យ ល្មមអាចបញ្ចូលក្នុងពពួកសៀវភៅសិក្សាផ្នែកមធ្យមភូមិបានឬទេ?

ក្រសួងអប់រំជាតិក៏បានយកចិត្តទុកដាក់ បញ្ជូនទៅគណៈកម្មការតាមសេចក្ដីសុំ ហើយគណៈកម្មការនេះ បានខំប្រឹងអស់ទាំងកម្លាំងកាយ ទាំងកម្លាំងចិត្ត ពិនិត្យយ៉ាងម៉ត់ចត់ ព្រមទាំងឲ្យយោបល់ដ៏ប្រសើរជាច្រើនដល់ខ្ញុំបាទ ក្នុងការកែច្នៃធ្វើយ៉ាងណា ឲ្យនិទានសន្និបាតមានសភាពរឹងរឹតតែប្រពៃឡើង គួរដល់ការសិក្សា សម្រាប់សិស្សថ្នាក់ទី ៦ និងទី ៥ ទំនើប នៃអនុវិទ្យាល័យ និងវិទ្យាល័យទាំងឡាយក្នុងកម្ពុជរដ្ឋ ។

ដូច្នេះ ខ្ញុំបាទសូមបង្អោនកាយគោរព និងថ្លែងកតញ្ញូតាដ៏ជ្រាលជ្រៅ ចំពោះក្រសួងអប់រំជាតិ និងគណៈកម្មការពិនិត្យសៀវភៅសិក្សាផ្នែកមធ្យមភូមិ សូមក្រសួងអប់រំជាតិ និងគណៈកម្មការ បានជួបប្រទះតែនឹងសុភមង្គលគ្រប់ប្រការជានិរន្តរតទៅ ។

ភ្នំពេញ ថ្ងៃទី ៣ សីហា ១៩៦៣

ដេង-ជ្រីវ

អតីតតំណាងរាស្ត្រមណ្ឌលព្រែកស្ដីស្រុកកោះធំ(កណ្ដាល)
នាយការិយាល័យនៃការផ្សាយនៅពុទ្ធសាសនបណ្ឌិត្យ
ក្រសួងធម្មការ ភ្នំពេញ ។

# អារម្ភកថា

នៅឆ្នាំ ១៩៤៦ ក្នុងសម័យដែលខ្ញុំចូលធ្វើជាសិក្សានារី នៅអនុវិទ្យាល័យនារី ហើយជាន់នោះ ព្រះអគ្គម្ចាស់ក្សត្រី យុគន្ធរពីងពាង ទ្រង់កាន់មុខតំណែងជាចាងហ្វាងសិក្សាធិការជាតិផង ជាចាងហ្វាងសាលាអនុវិទ្យាល័យនារីផង ទ្រង់មានព្រះបញ្ជាឲ្យខ្ញុំបាទរៀបរៀងសៀវភៅអានភាសាខ្មែរមួយប្រញាប់ ព្រោះនៅថ្នាក់ទី ៦ និងទី ៥ ទំនើប ខ្វះសៀវភៅអានបែបនេះ ដើម្បីយកមកបង្រៀនសិស្ស ៗ ក្នុងពេលនោះ សម្រាប់ថ្នាក់ទី ៦ និងទី ៥ ទំនើប មានសៀវភៅអានតែមួយបែប ដែលគេរៀបរៀងយូរយារណាស់មកហើយ គឺសៀវភៅ «សម្រាំង» ហើយសៀវភៅនេះទៀត មានចំនួនតិចពេក ថែមទាំងចាស់ទេចរឹល ដាច់បាត់ក្រប បាត់ទំព័រខ្វះផង ដែលជាហេតុនាំឲ្យការសិក្សាអក្សរសាស្ត្រខ្មែរ មានសេចក្ដីលំបាកជាពន់ពេក ទាំងខាងគ្រូ ទាំងខាងសិស្ស ៗ

ខាងក្រោយការទទួលព្រះបញ្ជាពីព្រះអគ្គម្ចាស់ក្សត្រី ខ្ញុំបាទបានយកកម្មវិធីខាងការសិក្សាអក្សរសាស្ត្រខ្មែរ នៅថ្នាក់ទី ៦ និងទី ៥ មក

ពិនិត្យមើល តើមានការបង្អុលប្រាប់ឲ្យបង្ហាត់សិស្ស យកក្នុងសាស្ត្រា ឬសៀវភៅណាខ្លះ ។ រួចខ្ញុំបាទស្រាវជ្រាវមើលនឹងខ្ចីសាស្ត្រាអស់នោះពីពុទ្ធសាសនបណ្ឌិត្យមកអានពិនិត្យសង្កេត ដើម្បីជ្រើសរើសនឹងដកស្រង់សេចក្តីខ្លះៗ ដែលអាចល្មមធ្វើជាអត្ថបទបង្រៀនបាន មានសាស្ត្រាស័ទ្ធ-សិល្បជ័យនឹងហង្សយន្តជាដើម ។ ប៉ុន្តែ ដោយសាស្ត្រាដែលមានចុះក្នុងកម្មវិធីខាងកិច្ចសិក្សា ពុំអាចឲ្យខ្ញុំដកស្រង់ធ្វើជាអត្ថបទ មានចំនួនគ្រប់គ្រាន់ដើម្បីរៀបរៀងជាសៀវភៅអានបាន ខ្ញុំបាទក៏ដើរទៅរកដកស្រង់ពីសាស្ត្រានិងសៀវភៅផ្សេងៗដទៃទៀត មានសៀវភៅ «សម្រាំង» និងគម្ពីរបាលីជាដើម ។

ឯការរៀបរៀងសៀវភៅអាននេះ បានជួបប្រទះនឹងឧបសគ្គជាច្រើន ឯឧបសគ្គធំជាងគេ គឺនៅត្រង់ស្ថានភាពខាងគ្រួសាររបស់ខ្ញុំបាទ ដែលមានសភាពមិនធូរទូលាយខាងសម្ភារៈ ។ ស្ថានភាពនេះហើយ ដែលធ្វើឲ្យសៀវភៅអានរបស់ខ្ញុំបាទ មានដំណើរយឺតយូរ ពុំបានសម្រេចកើតឡើងជារូបរាងដ៏ពិតប្រាកដដោយរហ័ស ។ តែទោះបីយ៉ាងដូច្នេះក៏ដោយ ការព្យាយាមរបស់ខ្ញុំបាទដើម្បីជាតិ នៅតែមានជីវិតតមក ពុំរលត់បង់ ដ្បិតខ្ញុំ

បាននិយមតម្រាប់តាមបុរាណភាសិតថា: "តក់តក់ ពេញបំពង់" ។ ឥឡូវ សៀវភៅណាដែលមានព្រះអង្គម្ចាស់ក្សត្រី យុគន្ធរពីងពាង ទ្រង់ជាមេផ្តួចផ្តើមគំនិតនោះ បានកើតជារូបរាងពិតប្រាកដហើយ ។

ឯអត្ថបទទាំងឡាយក្នុងសៀវភៅនេះ ចែកជាពីរក្រុម៖

ទី ១) ភាគអត្ថបទសម័យសតវត្សទី ១៨ នឹងទី ១៩

ទី ២) ភាគអត្ថបទសតវត្សទី ២០ នឹងអត្ថបទបកប្រែ

ខ្ញុំបាទសូមជំរាបបញ្ជាក់ថា ការបែងចែកអត្ថបទទៅតាមសម័យនេះ ធ្វើឡើង ដោយយោលទៅតាមការសង្កេតខ្លះ ទៅតាមការយល់ផ្ទាល់ខ្លួនខ្លះ ព្រោះដូចអស់លោកធ្លាប់បានជ្រាបស្រាប់ហើយថា អក្សរសាស្ត្រខ្មែរយើង ពីសម័យព្រេងនាយ មកដល់ខាងដើមសតវត្សទី២០ នៃគ្រិស្តសករាជ តិចណាស់ ដែលមានចង្អុលប្រាប់នាមអ្នកនិពន្ធ នឹងកាលបរិច្ឆេទនៃការតែង ម៉្លោះហើយ អ្នកស្រាវជ្រាវមែងមានការលំបាកពន់ពេក មិនដឹងយកអ្វីជាទីអាង រូបក៏និយមសន្និដ្ឋានតែរៀងៗខ្លួន ដោយយកការប្រៀបធៀប នឹងការសង្កេតជាប្រមាណ ។ ចំណែករូបខ្ញុំបាទក៏រាប់បញ្ចូលក្នុងក្រុមខាងលើនេះដែរ ។

ដូច្នេះ ប្រសិនបើមានការឆ្គាំឆ្គងខ្លះ ខ្ញុំបាទសូមអភ័យទោសអំពីសំ-ណាក់អស់លោកអ្នកប្រាជ្ញទាំងឡាយ ខាងអក្សរសាស្ត្រផង ហើយខ្ញុំសូមដាក់នាមដល់សៀវភៅអាននេះថា «និទានសន្និបាត» ។ ខ្ញុំសង្ឃឹមថា និទានសន្និបាតនេះនឹងបានជាទីពេញចិត្ត ព្រមទាំងជាហិតប្រយោជន៍ដល់សិក្ខាកាមកុលបុត្រ នឹងអស់លោកសាស្ត្រាចារ្យទាំងឡាយ ក្នុងប្រទេសកម្ពុជាទាំងមូលក្នុងសម័យមាសនៃសម្ដេចសហជីវិន ព្រះនរោត្តម សីហនុ ឧបយុវ-រាជ ព្រះបិតាឯករាជជាតិ នឹងតទៅអនាគត ។

ភ្នំពេញ ថ្ងៃទី ៣ សីហា ១៩៦៣

**ដេង-ង្រីប**

អតីតសិក្សានារី នៃអនុវិទ្យាល័យនារីភ្នំពេញ

# មាតិការឿង


| | | |
|---|---|---|
| ១– | ព្រះកេតុមាលា . . . . . | ទំព័រ ១ |
| ២– | ក្រាប់របនានគរវត្ត . . . . . | " ៥ |
| ៣– | ស្តេចដែលគួរគ្រងរាជសម្បត្តិ . . . | " ៧ |
| ៤– | ស្នេហ៍មិនស្មើស្និទ្ធ . . . . . | " ៩ |
| ៥– | កំណើតធនញ្ជ័យ . . . . . | " ១២ |
| ៦– | រឿងសត្វស្ការ . . . . . | " ១៦ |
| ៧– | មាយើងបានរួចចាកសេចក្តីស្លាប់ . . . | " ១៩ |
| ៨– | អាឡេវប្លន់ចោរ . . . . . | " ២២ |
| ៩– | ពាលទាល់ប្រាជ្ញ . . . . . | " ២៦ |
| ១០– | សេចក្តីកតញ្ញជាធំ . . . . . | " ៣០ |
| ១១– | សេចក្តីរំលឹកគុណ . . . . . | " ៣២ |
| ១២– | របៀបក្រងផ្កា . . . . . | " ៣៥ |
| ១៣– | ដំបូន្មានចំពោះធីតា . . . . . | " ៣៨ |
| ១៤– | មេមត់មើលជម្ងឺ . . . . . | " ៤១ |
| ១៥– | ដំបូន្មាននៃស័ន្ធសិល្បជ័យ . . . . | " ៤៥ |

១៦– ដំបូន្មាននៃមេត្រី . . . . . . . ទំព័រ ៤៧
១៧– អកញ្ញូសម្លាប់ខ្លួន . . . . . . . " ៥០
១៨– ឆ្កួតបីប្រការ . . . . . . . " ៥៣
១៩– ត្រូវបេះសន្សំទ្រព្យ . . . . . . " ៥៥
២០– តាទៅលើកដុប . . . . . . " ៥៨
២១– កិរិយាបួនយ៉ាង . . . . . . " ៦១
២២– ត្រូវមានកតញ្ញូតា . . . . . . " ៦៤
២៣– ត្រូវគេព្យាសាមគ្គីធម៌រវាងអ្នកក្រ . . . " ៦៧
២៤– គុណគ្រូ . : . . . . " ៦៩
២៥– ច្បាប់ដំបូន្មាននារី : . . . . " ៧២
២៦– កញ្ចប់បម្ភក់នគរវត្ត . . . . . . " ៧៥
២៧– បបកនឹងពពែ . . . . . . " ៧៨
២៨– ក្អែកនឹងហង្ស . . . . . . " ៨២
២៩– មិត្តវិទូក . . : . . . " ៨៥
៣០– សត្វចាបនឹងព្រាន . . . . . . " ៨៩
៣១– ទង់ទប្រាំប្រការ . . . . . . " ៩២

៣២– សត្វលានឹងនាយកប្បក: . . . . . ទំព័រ . ៩៦

៣៣– នន្ទបុរស . . . . . . . " ១០០

៣៤– កុកនឹងក្ដាម . . . . . . " ១០៤

៣៥– កុកនឹងក្ដាម (ត) . . . . . " ១០៦

៣៦– គ្រលីងគ្រលោងនឹងស្វា . . . . . " ១១១

៣៧– សេនកបណ្ឌិត . . . . . " ១១៤

៣៨– កេតីរ . . . . . . " ១១៨

៣៩– នាងឧម្មាទន្តី . . . . . " ១២៤

៤០– នាងឧម្មាទន្តី (ត) . . . . . " ១២៦

៤១– បុរសនឹងសេក . . . . . " ១៣២

៤២– ព្រានដំរី . . . . . . " ១៣៦

៤៣– ការដោះបញ្ហានៃកាឡាហ្វ . . . " ១៣៩

៤៤– បទនគរាជ . . . . . . " ១៤៥

# ភាគអត្ថបទ
# សតវត្សរ៍ ទី ១៨-១៩

# ព្រះកេតុមាលា

(បទកាកគតិ)

ព្រះកេតុសុរ្យវង្ស មៀងមើលរូបទ្រង់ អស់នាងកញ្ញា សើចលេង ក្អាកក្អាយ សប្បាយមហិមា មុខគួរស្នេហា ទាំងនាងទាំងឡាយ ។ ស្តេចគិតអាឡោះ អាល័យស្រណោះ ពុំបង់ឃ្លាតឆ្ងាយ គន់គិតជញ្ជឹង រំពឹងសព្វសាយ មានចិត្តគិតស្តាយ ទើបបានសួគ៌ា ។ សម្តេចសក្កា ទេវានមិន្ទោ ជាឆ្នើមទេវតា ទ្រង់លោមពជបុត្រ បរិសុទ្ធថ្លៃថ្លា ថាមាស-ពុំងា អ្នកកុំអាល័យ ។ បិតាធានា នឹងសាងប្រាង្គណ៍ប្រា-សាទឲ្យបុត្រ ថ្លៃ ឲ្យដូចប្រាសាទ ពេជយន្តប្រពៃ ដែលនៅនាឮ ស្ថានត្រៃត្រឹង្សា ។ ព្រះកេតុសុរិយោ វិសេសសេដ្ឋោ រូបឆោមថ្លៃថ្លា លើកគបន្ទិ ប្រណម្យ ឥន្ទ្រា មានព្រះបិន្ទា ត្រេកអរកន្លង ។ សម្តេចទេវរាជ ទ្រង់មានអំណាច លើសទេវតាផង ស្តេចប្រើវិស្ណុកម្ម តាមទ្រង់បំណង សាងមិនឲ្យគង ថ្វាយរាជកុមារ ។ ព្រះវិស្ណុកម្ម ព្រះទ័យបង់ចាំ ទទួលឱង្ការ ព្រះឥន្ទ្រ-ត្រាស់ប្រើ ឲ្យសាងប្រាង្គណ៍ប្រា-សាទថ្វាយកុមារ ក្នុងគ្រានេះម្តង ។ ទទួលព្រមស្រេច ទើបអង្គសម្តេច សហស្សនេត្រប្បង នាំអស់បរិពារ

ច្រើនក្រៃកន្ទង ចុះមកអឹងកង កាន់បានមនុស្សា ៗ ចាប់សាងព្រះគោ

ប្រសើរពេក អង្គមួយឯកា ទុកក្នុងរោងជ័យ ថែទាំរក្សា ទីបានសីមា

នៃព្រះពជបុត្រ ៗ ទើបកេណ្ឌរេហ៍ពល អនេកសកល ច្រើនក្រៃបំផុត

គ្រប់ជាតិនានា ដូចទឹកសមុទ្រ ចូលមកបំហុត ជួបជុំគ្នីគ្នា ៗ លុងលុះ

រួចស្រេច កាលនោះសម្តេច ព្រះវិស្ណុការ ចាប់ផ្តើមកសាង នូវពេង

ធម្មា អគ្គេយ៍បូព៌ា តំកល់ព្រះគោ ៗ នាក្នុងផ្ទាក់ខែង វិស្ណុចាត់ចែង ឲ្យ

យកសិលា សុទ្ធសឹងផែនថ្ម ក្ដីផ្ទុកសោផ្ដោ ដេរដាសពេញពោរ ជា-

អង្គប្រាសាទ ៗ គបដោយកំផែង ក្នុងក្រៅខ្វាត់ខ្វែង ជាជួរល្អស្អាត

មានទាំងខ្លោងទ្វារ ក្បូរក្បាច់ព្រោងព្រាត ភ្ញីរលើ្យរពាត មើលហាក់សួគ៌ា ៗ

មានរោងជុំនុំ ស្រះបួនត័ទ្ធជុំ ចតុទិសា មានទាំងហោត្រៃ ឆ្វេងស្ដាំផងណា

សម្រាប់ព្រះមហា-ក្សត្រាក្រសាល ៗ រោងទងជុំវិញ ជញ្ជាំងនោះមិញ

សុទ្ធសឹងថ្មដារ មានរូបចំឡាក់ ពាសពេញរាល់វាល ក្ដីប្រាលរន្ទាល

មុខគួរឲ្យស្ញែង ៗ ក្បាច់ក្បូរឧត្តម មុខនាគមុខព្រហ្ម ភ្ញាក់ដៃខ្វាត់ខ្វែង

រូបគោរូបសិង្ហ ប្រែប្រឹងសម្ញែង ស្ញេញស្ញាញយល់ស្ដែង ហាក់រស់វិស័យ ៗ

ប្រាសាទទាំងបួន រងរឿងមាំមួន រូបធ្លាក់ប្រពៃ ភ្ញីរលើ្យល្អគណាស់

ហាក់ដូចឋានត្រៃ-ត្រិង្សាវិស័យ មុខគួរឧបមា ។ បាកានប្រាសាទ ប្រសើរស្អាងស្អាត ជាទីអស្ចារ្យ ហេតុបុណ្យបារមី នៃរាជកុមារ សែនកោដិសំខ្យា អម្បូរពូជពង្ស ។ ព្រះវិស្ណុការ រណ្តាប់សព្វសារ-ពើផង ផ្ចិតផ្ចង់ រូបភាពកញ្ញា កាន់ផ្ការហង់ ឈរឈានតំរង់ គ្រប់ផ្ទាំងនានា គន់មើលគាងឃ្វាយ ត្រីសូលិ៍ពណ្ណរាយ សឹងកែវមុក្តា ពិទូរ្យពិទាយ រៀងរាយសោភា ក្រគិតគណនា ក្រស្តាល់សព្វសាយ ។ កំពូលស្រួចស្រង់ ផ្កាក់ក្បាច់សំយុង កញ្ចក់ព្រោងព្រាយ គ្រាលគ្រោមសឹងថ្ម ភ្លឺផ្ទុះយល់ឆ្ងាយ សុខក្សេមសប្បាយ អស់មនុស្សទេវតា ។ មានគ្រឿងប្រដាប់ ស្វាម្ពូ ស្រេចស្រាប់ ទៀនធូបមាលា អស់កោជនផង បំរុងបូជា នូវអស់ទេវតា នឹងរូបដីទេព ។

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ព្រះកេតុមាលា ។ ២) ព្រះកេតុសុរ្យវង្ស ។ ៣) រំពឹងសព្វសាយ ។ ៤) សក្កោ ។ ៥) ទេវានមិន្ទោ ។ ៦) វិសេសសេដ្ឋោ ។ ៧) ទេវរាជ ។ ៨) វិស្ណុកម្ម ។ ៩) សហស្សនេត្រ ។ ១០) អនេកសកល ។ ១១) បូល-មកបំហុត ។ ១២) សិណោ ។ ១៣) កេនទង ។ ១៤) សែនកោដិសំខ្យា ។ ១៥) គាងឃ្វាយ ។ ១៦) ត្រីសូលិ៍ពណ្ណរាយ ។

## ខ) សំនួរ

១) អ្នកណាយកព្រះកេតុមាលាទៅឋានសួគ៌? ។ ២) ហេតុដូចម្តេចបានជាព្រះឥន្ទ្រឲ្យព្រះកេតុមាលាត្រឡប់មកឋានមនុស្សវិញ? ។៣) ត្រង់ឃ្លាពាក្យថាៈ "ទើបកេណ្ឌរេហ៍ពល អនេកសកល ច្រើនក្រៃបំផុត គ្រប់ជាតិនានា ដូចទឹកសមុទ្រ ចូលមកបំហុត ដូចដុំគគ្គា" តើមានការផ្តុយទីនមហិទ្ធិរិទ្ធិ នៃព្រះឥន្ទ្រឬទេ? ។ ៤) ត្រង់ឃ្លាពាក្យចុងបំផុតៈ "មានគ្រឿងប្រដាប់ ស្លាម្ភូស្រេចស្រាប់ ទៀនធូបមាលា អស់កោដនផន បំរុងបូជា នូវអស់ទេវតា នឹងរូបដីទេព" តើមានអាការសមតាមបំណងដែលព្រះឥន្ទ្របាឲ្យព្រះពិស្ណុកម្ម មកកសាងប្រាសាទថ្វាយព្រះកេតុមាលាឬទេ?

## គ) វេយ្យាករណ៍

១) ចូរស្រង់ពាក្យដប់ម៉ាត់ ដែលប្រើក្លាយមក ពីភាសាបាលីឬសំស្ក្រឹត ។ ២) ចូរស្រង់ពាក្យដប់ម៉ាត់ គឺជាពាក្យដែលមានដាក់ «រ» នៅពីខាងមុខ ដូចជា «គ្រេកអរ» ។

# ក្បាច់រចនានគរវត្ត

(បទពំនោល)

ប្រដាប់បល្ល័ង្កប្រាំជាន់ ហាក់ទេពពេជយន្ត ព័ទ្ធព័ន្ធទៅដោយក្រ-វល្លិ៍ ៗ ដណ្ដើរកាច់កែវធ្លុះពណ៌ ពេនព័ទ្ធសសរ បវរពជប្រាសាទ ៗ ក្បូរក្បាច់រំលេចស្អាងស្អាត ធ្លាក់ធ្លៅត្រូវខ្នាត ជាប់ខ្នងបែងជាទង្កា ៗ ក្បែបក្បាយលាយលេចផលា ពីកង្ទុបុប្ផា ជារូបកញ្ញារេរាំ ៗ ខ្លះរូបពារេទន្ទាំ ខ្លះផ្លាស់លំនាំ ជារូបហង្សស្រង់ពោក្ខរ ៗ ខ្លះជារូបនាគមករ សុបណ្ណត្រេកអរ ធៀងតាមចាប់ពាសុក្រី ៗ លម្អការរចនាពិសី ពិសេសឥតបី ដូចមានវិញ្ញាណរូបរស់ ៗ ប្រាសាទបាសាណខ្ពង់ខ្ពស់ ល្បីចាំងទិសទស លើសទីដីដែននានា ៗ កក្ត្រព្រហ្មពុំមានអង្គា ទាំងបួនដូចជាទតទៅទូទាំងទិសទី ៗ ប្រាសាទទាំងបួនសោភី មានទ្វារគ្រប់ទី វិចិត្រដោយក្បូរសព្វសាយ ៗ មានរូបទេវីកែក្រាយ ឈ្មងធ្មៀងផ្អៀងកាយក្លាយទេពអប្សរសួគ៌ា ៗ គ្រប់អង្គបញ្ចង្គសោភា ឈរឈមរក្នា លេងលើប្រាសាទនោះហោង ៗ កេសាពាក់ផ្កាកម្រង ចំពៀនកែវគងពាសពេញស្បូវដើងដៃ ៗ រូបទាំងរយពាន់ក្រាស់ក្រៃ ឬហួសវិស័យ

វិសេសវិសាលឥតខ្ចោះ ។ តាមផ្ទាំងជញ្ជាំងកៀនកោះ ចម្លាក់ចម្លោះ ជារឿងរាមកេរ្តិ៍អតីត ។ ឋរៈយុគគឺស្តេចទ្រង់ស័ង្ខ លើកពលទៅច្បាំង តតាំងដណ្តើមសីតា ។ ក្រិតយុគទុកជាមជ្ឈិមា ស្តេចកេណ្ឌពលស្វា ជូនទៅលង្កាស្រុកយក្ស ។ កលិយុគព្រួយទុក្ខគ្រោះថ្នាក់ រឿងព្រះរាមលក្សណ៍ ធ្លាក់តមកដល់ឥឡូវ ។ គេឃើញយក្សស្លាប់ច្រើនគូរ ពលស្វាស្រមូវ រុកពនទន្ទ្រានហាវហាន ។

## ក) ពន្យល់ពាក្យ

១) ខ្ចោះ ។ ២) មករ ។ ៣) សុបណ្ណ ។ ៤) កំសុក្រ ។ ៥) លញ្ចការ ។ ៦) ប្រាសាទបាសាណខ្ពង់ខ្ពស់ ។ ៧) សោភី ។ ៨) អប្សរ ។ ៩) សួរគ៌ ។ ១០) ក្រិតយុគ ។ ១១) ឋរៈយុគ ។ ១២) កលិយុគ ។

## ខ) សំនួរ

១) អ្នកនិពន្ធប្រៀបផ្ទឹមប្រាសាទនគរវត្ត ទៅនឹង "ប្រាសាទពេជ-យន្ត" ដោយប្រការម្តេច? – ២) "ក្បូចក្បាចលាចលេចផ្កា ពីកនិបុប្ផា ជារូបកញ្ញារេរាំ" – "គ្រប់អង្គបញ្ចគ្គសោភា ឈរឈមរគគ្នា លេងលើប្រាសាទនោះបាន" ពាក្យទាំងពីរបទនេះ បង្អួលបង្ហាញចំពោះអ្នកអានឱ្យក្បាប់

ចម្លាក់ខ្មែរ ប្រកបដោយសម្រស់ គួរជាទីចាប់ចិត្តបែបណា?– ៣) «សិតា» គឺជាអ្នកណា?– ៤) ហេតុអ្វីក៏មានរឿងដណ្តើម «សិតា»?– ៥) ចូរពិនិត្យមើល តើឃ្លាពាក្យត្រង់ណាខ្លះ ដែលធ្វើឲ្យអ្នកទាក់ចិត្ត ព្រមទាំងមានលំនាំហាក់ដូចជារូប ប្រកបដោយចលនាមែន ៗ?

---

# ស្តេចដែលគួរគ្រងរាជសម្បត្តិ

**នៅនានគរមួយ** ព្រះមហាក្សត្រជាអម្ចាស់ជីវិតលើត្បូង ទ្រង់មានព្រះរាជបុត្របីព្រះអង្គ កាលមានវ័យធំចំរើនឡើងហើយ បានចេញទៅស្វែងរករៀនសិល្បសាស្ត្រ ព្រះអនុជទ្រង់រៀនសិល្បធ្នូ ព្រះរៀមកណ្តាលរៀនក្បួនហោរា ព្រះរៀមច្បងបង្អស់ រៀនគិតការយកព្រះទ័យទុកដាក់នឹងរេហ៍ពលសកលយោធាផងទាំងពួង ។ ព្រះរាជបុត្រទាំងបីព្រះអង្គ រៀនបានចេះចប់ សព្វគ្រប់ប្រការទីទៃ ៗ ហើយ ក៏វិលមកនគរសម្តេចព្រះវររាជបិតាវិញ ព្រះវររាជបិតាទ្រង់ព្រះតម្រិះថា បើដូច្នេះ តើអញនឹងឲ្យកូនណាសោយរាជ្យតវង្ស ស្នងអញជាឪពុក ព្រះអង្គទ្រង់ព្រះចិន្តាពិចារណា

ពុំដាច់ស្រេចក្នុងព្រះរាជហឫទ័យឡើយ ទើបឲ្យព្រាហ្មណ៍ អ្នកប្រាជ្ញ រាជ-បុរោហិត នូវអស់មុខមន្ត្រី សេនាបតី កវីបណ្ឌិត ព្រឹទ្ធាចារ្យផង ទៅដណ្ដឹងសួរមហាឫសី ថាអ្នកទាំងពីរនេះ គួរឲ្យនរណា ជាស្ដេចសោយរាជ្យ គ្រងស្នងអង្គអញដ៏ជាឪពុក ។ អ្នកទាំងឡាយបានទទួលព្រះរាជឱង្ការ ក៏នាំគ្នាទៅគាល់មហាឫសី ពិតពុទ្ធដីកា តាមលំអានដំណើរព្រះរាជឱង្ការ គ្រប់ប្រការព្រះមហាឫសី ប្រកបដោយបញ្ញាវៃ ឆ្លើយថា ព្រះរាជបុត្រាដែលចេះប្រដាប់ប្រដាៈ យកព្រះទ័យទុកដាក់នឹងរេហ៍ពលសកលយោធា គួរបានជាស្ដេចគ្រងស្នងព្រះវររាជបិតា អង្គឯណាដែលចេះសិល្បជ្ឈ គួរតាំងទុកជាមហាសេនាបតី ឯអង្គទ្រង់ក្សួនហោរាសាស្ត្រនេះ គួរទុកជាមហាឧបរាជតែងនឹងយង់យល់គាប់ខុស ស្នងព្រះអង្គស្ដេច ជាសួរេចនូវប្រការអម្បាលនេះឯងហោង ។

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) សិល្បសាស្ត្រ – ២) ព្រះអនុជ – ៣) ព្រះរៀម – ៤) ព្រាហ្មណ៍ – ៥) បុរោហិត – ៦) កវី – ៧) បណ្ឌិត – ៨) ព្រឹទ្ធាចារ្យ – ៩) ឫសី – ១០) អម្បាលនេះ ។

## ខ) សំនួរ

ចូរអធិប្បាយៈ ហេតុដូចម្ដេច បានជាលោកតាមហាឫសី បង្គាប់ឲ្យតាំងព្រះរាជបុត្រច្បងជាស្ដេច ព្រះរាជបុត្រកណ្ដាលជាឧបរាជ ព្រះរាជ-បុត្រពៅជាមហាសេនាបតី?

---

# ស្នេហ៍មិនស្មើស្និទ្ធ

មានបុរសបួននាក់ ទៅស្វែងរករៀនសិល្បសាស្ត្រ អំពីព្រាហ្មណ៍ម្នាក់ឈ្មោះទិសាបាមោក្ខ នៅឯតក្កសិលា មហានគរ បុរសមួយរៀនហោរ បុរសមួយរៀនសិល្បបាញ់ បុរសមួយរៀនមន្តមុជទឹក បុរសមួយទៀតរៀនមន្តជប់ឲ្យរស់រូបវិញ ។ ទាំងបួននាក់ សឹងរៀនទីទៃៗចប់ស្រេចហើយ ក្រាបលាអាចារ្យទិសាបាមោក្ខ ជាគ្រូដើរទៅ គាប់ជួនល្ងាចហើយ ឈប់ខានសម្រាន្តដេកនៅឆ្នេរសមុទ្រ លុះព្រឹកឡើង បុរសចេះហោរ និយាយទៅបុរសទាំងបីថា អ្នកអើយ ថ្ងៃនេះមានសត្វឥន្ទ្រី ពាំនាំយកកូនស្រីស្ដេចមួយព្រះអង្គ ពីពារាណសីមហានគរ ហើរមកទៀប

លំនៅនេះហោង ៗ បុរសទាំងបួននាក់ដឹងដូច្នោះហើយ ក៏ឃ្មាំចាំមើលគ្រប់ទិសានុទិស ឮដ៏កាលនោះ ពុំយូរឡើយ ឥន្ទ្រីក៏ពាំនាងហើរមកទៀតប្រាកដដុតដូចហោរទាយនោះមែន រីឯបុរសបេះបាញ់ ដំឡើងធ្នូ បាញ់ត្រូវឥន្ទ្រីនោះ ធ្លាក់នាងអំពីមាត់ចុះទៅក្នុងទឹកសមុទ្រ អ្នកដែលបេះមុជទឹកក៏មុជទៅយកនាងឡើងមក បានដូចបំណង ឯអ្នកបេះសិល្បជប់ឲ្យរស់ក៏មកជប់នាងឲ្យរស់ឡើងវិញ ៗ កាលបើនាងមានជីវិតរស់ឡើងវិញហើយអស់អ្នកទាំងបួននោះ ក៏ដណ្ដើមគ្នាចង់បាននាងធ្វើជាភរិយាទីទៃៗរៀងខ្លួនៗ អ្នកទាំងបួននោះ នាំគ្នាទៅដល់ចៅក្រម ប្ដឹងដោយដំណើរខ្លួនតាមចំណាំស្រេចហើយ ទើបសួរថា បើដូច្នោះ តើនាងនេះត្រូវបានទៅជាប្រពន្ធនរណា ចៅក្រមនឹងជំនុំពិចារណាពុំបានឡើយ ទើបនាំចៅទាំងបួននោះឡើងទៅក្រាបបង្គំទូល សម្ដេចព្រះមហាក្សត្រាធិរាជ ដោយដំណើរសព្វគ្រប់ប្រការ ហើយព្រះអង្គទ្រង់ព្រះចិន្ដាពិចារណាឈ្វេងយល់ ក្នុងព្រះរាជហឫទ័យជាស្រេច មានព្រះរាជបន្ទូលថា គុណព្រះស្ដែងទាំងបួននេះ សឹងគាប់ប្រសើរណាស់ ហើយទ្រង់ត្រាស់បង្គាប់ថាឯបុរសបេះហោរទុកជាគ្រូ បុរសបេះបាញ់ទុកជាឪពុក បុរសដែលបេះ

ព្រោះទុកជាម្ដាយ ចំណែកបុរសចេះមុជទឹក ថាតៀតបានស្លាប បានកាន់អង្គនាង បីបមថ្នមទ្រយកនាងពីក្នុងទឹកឡើងមក ហេតុដូច្នោះ ឲ្យបុរសនោះបាននាងជាប្រពន្ធ ។

លុះចំណេរតមក បុរសជាប្ដីនាងបានជាស្ដេច ហើយចិញ្ចឹមរក្សាអ្នកទាំងបីជាមិត្ត ដោយនូវគុណសម្ដេចព្រះមហាក្សត្រាធិរាជបង្គាប់នោះឯសម្ដេចព្រះមហាក្សត្រាធិរាជកាត់សេចក្ដីដូច្នេះនេះ ហៅថាសុគតិគមន៍ហោង ។

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ស្នេហ៍មិនស្មើស្និទ្ធ ។ ២) ទិសាបាមោក្ខ ។ ៣) តក្កសិលា ។ ៤) សត្វឥន្ទ្រី ។ ៥) ពារាណសី ។ ៦) ទិសានុទិស ។ ៧) ទ្រង់ព្រះតម្រិះ ។

## ខ) សំនួរ

១) ហេតុអ្វីជំនាន់បូរាណ បើកាលណាគេចង់រៀនវិជ្ជាអ្វី ៗ គេទៅតែនគរតក្កសិលា ?

២) តាមការណ៍ពិត បើមនុស្សស្លាប់ គេអាចព្រោះឲ្យរស់វិញបានឬទេ ?

៣) ដោយប្រការម្ដេច បានជាព្រះមហាក្សត្រទុកបុរសចេះហោរជាគ្រូ បុរសចេះបាញ់ជាឪពុក បុរសចេះព្រោះជាម្ដាយ ?

## គ) គតិរឿង

ក្នុងរឿងនេះ តើអ្នកនិពន្ធមានបំណងនឹងនិទស្សន៍យ៉ាងណា ?

---

# កំណើតធនញ្ជ័យ

នេះនឹងនិយាយពីរឿងធនញ្ជ័យ កាលដើមឡើយ មកចាប់កំណើតក្នុងពោះម្ដាយ ៗ ដេកទៅយល់សប្តិនាវេលាទៀបព្រឹក ដូចជាយល់ស្វង យល់សប្តិឡើងដូង បេះបានទាំងផ្លែ យល់សប្តិឃើញខែ ១ នោះពេញបូណ៌មី នាងនោះភ្ញាក់ឡើងពីដេកគិតថា សប្តិនេះល្អណាស់ បើដូច្នេះ អញនឹងទៅឲ្យហោរមើល ឲ្យបានដឹងជាសប្តិនោះល្អឬអាក្រក់ គិតស្រេច យកទៀនធូបដើរចេញទៅ ជួនជាថ្ងៃនោះ អ្នកហោរមិននៅ ៗ តែប្រពន្ធ នាងនោះទៅដល់ផ្ទះហោរហើយសួរថា អ្នកហោរនៅហ្នឹងទេ ប្រពន្ធហោរប្រាប់ថា មិននៅទេ រកគាត់មានការណ៍អ៊ីនាង ៗ នោះប្រាប់ថា មករកគាត់ឲ្យទាយសប្តិ ត្បិតខ្ញុំដេកទៅយល់សប្តិទៀបពេលព្រឹក ហាក់ដូចយល់ស្វង យល់សប្តិឡើងដូងបេះបានទាំងផ្លែ យល់សប្តិឃើញខែ១ៗនោះពេញបូណ៌មី ប្រពន្ធហោរ

ស្លាប់ដឹងសព្វគ្រប់ ជានាងនោះនឹងមានកូន ១ ជាប្រុស ហើយនឹងបាន
ជាស្តេច ដឹងដូច្នោះហើយ គិតថា អញនឹងទាយឲ្យទៅជាខ្ញុំគេ គិតស្រេច
ទាយថា នាងនឹងមានកូនប្រុសមួយនឹងទៅជាខ្ញុំគេ នាងនោះបានឮប្រពន្ធ
ហោរទាយដូច្នោះហើយ ក៏លាវិលមកផ្ទះវិញ ។

ដល់សម្រាលកូននោះមក ប្រុសមែន ឲ្យឈ្មោះថាធនញ្ជ័យ ។ បាន
អាយុប្រាំពីរឆ្នាំ ក៏ដើរទៅលេងខាងផ្ទះមហាសេដ្ឋីសព្វៗថ្ងៃ ឯប្រពន្ធមហា-
សេដ្ឋីត្បាញលើផ្ទះ បោះត្រល់ទៅធ្លាក់ទៅដី ក្រឡេកទៅឃើញធនញ្ជ័យ
លេងនៅនោះស្រែកហៅថា អាជ័យរើសត្រល់ឲ្យអញ ទើបធនញ្ជ័យសួរថា
បើខ្ញុំរើសត្រល់ជូន តើឲ្យរបស់អ្វីខ្ញុំ ប្រពន្ធមហាសេដ្ឋីថា អញឲ្យអំបុកឯង
ស៊ី ធនញ្ជ័យថាឲ្យតិចឬច្រើន នាងប្រពន្ធមហាសេដ្ឋីថា អញឲ្យច្រើន
ទើបធនញ្ជ័យរើសត្រល់ហុចទៅ ហើយអង្គុយចាំទារអំបុកអំពីប្រពន្ធមហា-
សេដ្ឋីថា ឲ្យអំបុកមកខ្ញុំៗនឹងទៅផ្ទះ ឯប្រពន្ធមហាសេដ្ឋីឲ្យយកអំបុកមក
ឲ្យធនញ្ជ័យៗថាតិចណាស់ ឲ្យច្រើនមកទៀត ទើបប្រពន្ធមហាសេដ្ឋីឲ្យ
យកអំបុកមកឲ្យមួយកញ្ជើទៀត នោះធនញ្ជ័យថាឲ្យច្រើនមកទៀត ប្រពន្ធ
មហាសេដ្ឋីថាអញឲ្យច្រើនអស់ប៉ុណ្ណោះហើយ ធនញ្ជ័យខឹងយំទារតែអំបុក

ច្រើននោះ ឮទៅដល់មហាសេដ្ឋីៗដើរចូលមកមើល ហើយសួរថា អាជ័យ ថ្វីក៏យំ ទើបប្រពន្ធមហាសេដ្ឋីប្រាប់ថា ខ្ញុំឲ្យរើសត្រល់ឲ្យខ្ញុំៗថាឲ្យអំបុកច្រើន ឥឡូវខ្ញុំឲ្យមួយកញ្ជើហើយ វានៅតែថាឲ្យៗច្រើនទៀត ឥឡូវនេះវាអង្គុយតែយំ ទើបមហាសេដ្ឋីថា ឱឯងមិនដឹងចិត្តអាជ័យទេ មានតែអញឲ្យវា ទើបវាព្រមចូលចិត្ត មហាសេដ្ឋីថា អាជ័យមកនេះ អញនឹងឲ្យអំបុកអាឯងច្រើន ធនញ្ជ័យឮមហាសេដ្ឋីហៅដូច្នោះហើយ ក៏ដើរទៅតាមមហា-សេដ្ឋីៗឲ្យយកបង្អើមួយមកដាក់អំបុក វាចឲ្យពេញបានជាពីរដុំ ហើយសួរថាអាជ័យ អាមើលអំបុក ឯណាច្រើន ទើបអាជ័យថានេះច្រើន នោះតិចមហាសេដ្ឋីថា បើឯណាច្រើន អាឯងយកច្រើននោះចុះ ធនញ្ជ័យយកអំបុកនៅក្នុងបង្អើ ទើបចូលចិត្តថា អញបាញ់ប្រាជ្ញាមហាសេដ្ឋីនេះហើយ បើដូច្នោះអញនឹងផ្ចាញ់ប្រាជ្ញាគាត់វិញឲ្យបាន ទើបអញសុខចិត្ត ធនញ្ជ័យគិតដូច្នោះស្រេចហើយ ក៏វិលទៅផ្ទះវិញ ប្រាប់ម្តាយថា អ្នកម៉ែទៅយកប្រាក់មហាសេដ្ឋី ហើយឲ្យខ្ញុំទៅនៅជាខ្ញុំបម្រើគេចុះ ខ្ញុំនឹងបម្រើលោកតាមចិត្តខ្ញុំប៉ង ខ្ញុំមិននៅនឹងអ្នកម៉ែទេ ៗ ម្តាយឮកូនថាដូច្នោះហើយ ក៏និយាយថាអ្នកមាសម្តាយៗគ្មានជំពាក់បំណុលគេសោះ ម្តេចក៏ឲ្យម្តាយយកកូនទៅនៅ

ជាខ្ញុំគេ ។ ទើបធនញ្ជ័យប្រាប់ម្ដាយថា ខ្ញុំចង់ទៅផ្ចាញ់ប្រាជ្ញាមហាសេដ្ឋីទៅតើ ។ ម្ដាយស្ដាប់ហើយ ក៏ព្រមទៅយកប្រាក់មហាសេដ្ឋី ហើយឲ្យកូនចូលទៅនៅជាខ្ញុំបំរើ អំពីថ្ងៃនោះឯង ។

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ធនញ្ជ័យ (ធៈនាញ់ជៃ) – ២) យល់សប្ដិ – ៣) បូណិមី (បូរណៈម៉ី) – ៤) អំបុក – ៥) ព្រមចូលចិត្ត ។

## ខ) ផែនការ

ចូរពិនិត្យរកសង្កាត់នៃអត្ថបទនេះ តើមានប៉ុន្មាន? ហើយក្នុងសង្កាត់នីមួយៗគេពោលអំពីអ្វី?

## គ) សំនួរ

១) យ៉ាងដូចម្ដេច បានជាម្ដាយធនញ្ជ័យនឹកស្មានថាយល់សប្ដិរបស់ខ្លួនល្អ? – ២) ប្រពន្ធតាហោរយល់ថាយល់សប្ដិនេះល្អដែរ ព្រោះហេតុអ្វី? – ៣) ដោយយល់ឃើញប្រការម្ដេច បានជាប្រពន្ធតាហោរ ពាយឲ្យកូនទាំងនោះទៅជាខ្ញុំគេ? – ៤) ម្ដាយធនញ្ជ័យវិលមកផ្ទះវិញ មិននៅចាំឲ្យ

គាហោរពាយយល់សប្តិឲ្យត្រឹមត្រូវ តើដោយប្រការម្ដេច ? – ៤) ដោយហេតុអ្វី បានជាធនញ្ជ័យចាញ់ប្រាជ្ញាមហាសេដ្ឋី ?

### ឃ) អត្ថសេចក្ដី

កំណាព្យនេះ តើមានគតិប៉ុន្មានយ៉ាង ដោយអនុលោមទៅតាមការនិយមរបស់ខ្មែរយើង ព្រមទាំងតាមច្បាប់មនុស្សធម៌ ។

### ង) វេយ្យាករណ៍

១) ចូរសង្កេតមើលប្រយោគកំណាព្យ តើអ្នកនិពន្ធសរសេររបៀបដូចម្ដេច ?
២) ចូរកាត់ប្រយោគកំណាព្យជាវគ្គ ទី១ ឲ្យជាប្រយោគខ្លីៗ ដោយបន្ថែមវណ្ណៈ ។

---

## រឿងសត្វស្ទារ

( បទពាក្យគតិ )

មាយើងបានសម្លាប់ពស់ដែលបំរុងនឹងចឹកស្ដេច ឈាមពស់ខ្ទាយខ្ទាត់ទៅប្រឡាក់ព្រះស្ដនៃព្រះអគ្គមហេសី ។ ដោយមានសេចក្ដីគោរពចំពោះព្រះមហេសី មាយើងយកអណ្ដាតលិទ្ធឈាមនោះចេញ ព្រះនាងក្រាបទូលព្រះស្វាមី ថាមាយើងចង់ប្រមាថមើលងាយ ។ ទ្រង់ខ្ញាល់ពេក ព្រះរាជឲ្យគេយកមាយើងទៅសម្លាប់ ។

ឆ្នាំទារនោះណា បង្ខានអាជ្ញា ឈ្មោះឈប់របស់ ទើបនាំទំពាន
មែនមានបានយល់ ប្រាយប្រាប់អស់គល់ និងពេជ្យឃាដហោង ។
បងអើយនិយាយ កាលពីព្រេងនាយ ទុកជាទំនង មុនមានស្ត្រីម្នាក់
មានកូនមួយផង នៅខ្ទមតូចហោង នាងតែងរក្សា ។ រីនាងនោះនៃ
មានសម្បុរសក្រៃ និងសត្វនានា ចិញ្ចឹមស្ការផង ស្រឡាញ់រក្សា
ទុកប៉ុនតែស្ការ និងកូននោះនៅ ។ ផ្តេកក្នុងអង្រឹង នោះហើយនាងទឹង
យាត្រាចេញទៅ ក្សិណទើបកាលនោះ ក្រៅនោះកំឡៅ ពស់ពិស
ឃោរឃៅ កំណាចយង់ឃ្នង់ ។ វារលូនលាំ ចូលមកទឹងខាំ កូន
នោះមរណ៍ហោង ស្ការយល់ពស់ពិស ទ្រុះទ្រើសគន្ធង ស្ការប្រខាំ
ផង ទឹងពស់នោះណា ។ កាលនោះពស់ពាល ប្រខាំនរនៀល
ស្ការខាំមរណា ម្ចាស់ត្រឡប់មក ក្សិណស្ការនោះរា រត់ដោយមាគ៌ា
ទៅទទួលហោង ។ រីស្ត្រីម្ចាស់ស្ការ យល់ឈាមរន្ទាល នៅខ្ទមនោះ
ផង ប្រមាណគិតថា ស្ការកាចកន្ទង ខាំកូនជាម្ដង មិនឈាមអ្វី
ឡើយ ។ ខឹងធុរធៀបធាប់ ពាក់ស្ការនោះស្លាប់ បោះបង់សៀត
ហើយ ចូលទៅមើលកូន មិញសូន្យឥតត្រើយ ពិតពុំទេឡើយ យល់

ពស់មរណា ៗ ទើបគិតឯងយល់ ថាពស់កាចសល់ ខឹងខាំបុត្រត្ង ស្ការការបុត្រនោះ ប្រខាំសោះសា យល់ស្នាមដាក់ដា បន្ទាល់ទៀងក្ដាត់ ៗ ទើបគិតស្ដាយស្ការ ស្ដាយកូនសង្សារ សូន្យសោះគំនិត សោកឯងស្ដាយឯង នោះក្រែងមហាក្សត្រ នឹងបង់គំនិត ស្ដាយដូច្នោះហោង ៗ ហេតុអញពុំបង់ បើកបើចៅចំ ខុសច្បាប់គន្លង ចៅទៅទ្វារទៀត វែអញនេះម្ដង មិនបើកឡើយហោង និយាយយើងមាន ៗ

---

## ក) ពន្យល់ពាក្យនឹងសំនួរវោហារ

១) ឆ្មាំទ្វារ ៗ ២) អាជ្ញា ៗ ៣) ទុកប៉ុនតែស្ការនឹងកូននោះនៅ ៗ ៤) លលាំ ៗ ៥) ខឹងធុរធៀបឆាប់ ៗ ៦) មិញសូន្យឥតត្រើយ ៗ

## ខ) សំនួរ

១) ឆ្មាំទ្វារ បន្ទប់អាជ្ញាឲ្យឈរឈប់របល់ : ដែលឆ្មាំទ្វារហ៊ានធ្វើដូច្នេះ ដោយអាងអ្វី? — ២) ហេតុអ្វីក៏ឆ្មាំទ្វារចាំនាំនិទានមកប្រាប់ដល់ពេជ្ឈឃាដ? — ៣) ឆ្មាំទ្វារថា: «នោះក្រែងមហាក្សត្រ នឹងបង់គំនិត ស្ដាយដូច្នោះហោង» តើនឹងស្ដាយដូចអ្វី?

### គ) អត្ថរសទូទៅ

និទាននេះ នឹងបានជាគតិដល់អ្នកអានទាំងឡាយដូចម្ដេច ? បើសម័យបច្ចុប្បន្ន ចំពោះរឿងនេះ តើនឹងត្រូវចាត់វិធានការបែបណា ?

---

## មារយើងបានរួចជាកសេចក្ដីស្លាប់

(បទព្រហ្មគីតិ)

កាលនោះអង្គមហាក្សត្រ ព្រះព្រហ្មទត្តតើនឡើងហើយ ព្រះទ័យសោកពុំស្បើយ គិតទៅដល់មាយើងថា ៗ មាយើងមានគុណក្រៃ កាលនៅព្រៃមានតែមា-យើងឥតឯគណនា ក្រៃអំពីមាយើងឡើយ ៗ ឥឡូវនេះអញប្រើ ឲ្យគេធ្វើគុតគាត់ហើយ គេកាប់ឬនៅឡើយ ស្ដាយដោយឥតពិចារណា ៗ ស្ដេចត្រាស់ឲ្យអាមាត្យ រត់ខ្ចីឃាតទៅឃាត់ថា ព្រះអង្គទ្រង់មេត្តា ដោយករុណាពុំពិឃាដ ៗ កាលនោះឯអាមាត្យ ក្រញ្ញក្រាបបាទរត់នរនាទ ទៅកាន់អស់ពេជ្ឈឃាដ នៅនាទ្វារឧត្តរនោះ ៗ ទើបនាំមាយើងយក វិលវិញមកថ្វាយក្សត្រស្មោះ ទើបស្ដេចបន្ទូលផ្ដោះ ជណ្ដឹង

ទៅមាយើងណា ៗ មាយើងទូលដោយស្បៀត ថាបពិត្រព្រះពជា

កាលកន្ទយប់មិញណា ពស់ចង់ខាំមហាក្សត្រថ្ងៃ ៗ ខ្ញុំកាប់ពស់អន្តរាយ

លោហិតខ្ចាយពីក្រោមក្រែ ពេញព្រះថនានៃ វរទេវីពិសេសសល់ ៗ

ខ្ញុំពុំហ៊ានប្រមាថ ឡើយព្រះបាទឲ្យអំពល់ ទឹងយកដៃជិតដល់

សោកពុំគួរហើយខ្ញុំ ៗ យកអណ្តាតលិទ្ធឈាម កូវកើតខ្លាមពិតពុំសម

ជ្រាបដល់ព្រះអង្គអ-ម្ចាស់ឲ្យចាប់ចងទៅកាប់ ៗ ខ្ញុំទឹងទូលក្សត្រក្សាន្ត

ពាស់ពុំបានក្រែងខុសច្បាប់ សំណឹកបើទឹងស្លាប់ តាមអំពើកម្មវេរា ៗ

ស្តេចស្តាប់ផណ្តឹងផ្តោះ បើដូច្នោះខ្មោចពស់ណា ចៅទុកចោលឥតការ

ឥឡូវចៅប្រាប់អញហោង ៗ មាយើងទូលវិងខ្លី ខ្ញុំទុកឲ្យក្រោមគ្រែហោង

តាំងបីកំណាត់ផង ក្រោមមណ្ឌលព្រះកូបាល ៗ ទើបស្តេចឲ្យទៅយក

ខ្មោចពស់មកមែនវិសាល ដើចៅមាយើងកាល នោះព្រះអង្គជឿជាក់

ស្តែង ៗ ក្សត្រថ្ងៃបុណ្យប្រើនខ្ពស់ យល់ខ្មោចពស់រឹងស្ងប់ស្ងែង ព្រឺព្រួច

ប្រុងគ្រញែង ព្រះសិរសីបន្ទូលថា ៗ ចៅអើយហេតុអញខ្លៅ ធ្វើទោសចៅ

ឥតករុណា កុំចៅយកទោសា អញទទួលទោសខុសហើយ ៗ ទើប

ស្តេចគិតគុណក្រៃ ឲ្យយសថ្ងៃឥតផ្ទឹមឡើយ នៃមាយើងជាត្រើយ ជា

### គ) អត្ថសេទូទៅ

និទាននេះ នឹងបានជាគតិដល់អ្នកអានទាំងឡាយដូចម្តេច ? បើសម័យបច្ចុប្បន្ន ចំពោះរឿងនេះ តើនឹងត្រូវចាត់វិធានការបែបណា ?

---

## មារយើងបានរួចចាកសេចក្តីស្លាប់

(បទព្រហ្មគីតិ)

កាលនោះអង្គមហាក្សត្រ ព្រះព្រហ្មទត្តតើនឡើងហើយ ព្រះទ័យសោកពុំស្បើយ គិតទៅដល់មាយើងថា ៗ មាយើងមានគុណក្រៃ កាលនៅព្រៃមានតែមា-យើងឥតឯគណនា ក្រៃអំពីមាយើងឡើយ ៗ ឥឡូវនេះអញប្រើ ឲ្យគេធ្វើគុតគាត់ហើយ គេកាប់ឬនៅឡើយ ស្ដាយដោយឥតពិចារណា ៗ ស្ដេចត្រាស់ឲ្យអាមាត្យ រត់ខ្ចីឃាតទៅឃាត់ថា ព្រះអង្គទ្រង់មេត្តា ដោយករុណាពុំពិឃាដ ៗ កាលនោះឯអាមាត្យ ក្រួញក្រាបបាទរត់ទរនាទ ទៅកាន់អស់ពេជ្ឈឃាដ នៅនាទ្វារឧត្តរនោះ ៗ ទើបនាំមាយើងយក វិលវិញមកថ្វាយក្សត្រស្នោះ ទើបស្ដេចបន្ទូលផ្ដោះ ជណ្ដឹង

## ឃ) វេយ្យាករណ៍

១) ចូរស្រង់សព្ទទាំងឡាយ ដែលប្រើក្លាយមកពីបាលីនឹងសំស្ក្រឹត ក្នុងអត្ថបទនេះ ។

២) ក្នុងសេចក្ដីនៃពាក្យកាព្យ មុនបទចុងបំផុត ត្រង់ពាក្យថា: «ឲ្យយសថ្ងៃឥតផ្ដឹមឡើយ «នៃ» មាយើងជាត្រើយ» ចូររកអាយតនិបាតដទៃមួយមកដាក់ជំនួស «នៃ» ឲ្យត្រឹមត្រូវតាមច្បាប់វេយ្យាករណ៍ ។

៣) ចូរអធិប្បាយបញ្ជាក់នូវការប្រើ «នៃ» នឹង «ដល់» ដែលជាអាយតនិបាត មានន័យផ្សេងគ្នា ព្រមទាំងធ្វើប្រយោគជាឧទាហរណ៍ ដោយយកអាយតនិបាតទាំងពីរនេះ មកប្រើបញ្ចូលជាមួយ ។

---

## អាឡេវប្លន់ចោរ

មានមួយថ្ងៃ អាឡេវនាំប្រពន្ធចុះទូក រត់ចោលដីដូនក្អេកទៅៗប្រទះនឹងចោរប្រាំរយនាក់ ឯចោរទាំងប្រាំរយនោះ តែងតែនៅចាំប្លន់អ្នកទូកអ្នកដំណើរ ដែលដើរទៅរកស៊ីតែសព្វថ្ងៃ លុះឃើញទូកបែរទៅដល់ ក៏គិតប្លន់

យកទ្រព្យរបស់ ៗ អាឡេវដឹងថាចោរចង់ប្លន់យករបស់ខ្លួនដូច្នោះ ក៏ចូលទូកទៅកណ្ដាលពួកចោរ ហើយឡើងទៅនិយាយនឹងមេចោរថា អស់អ្នករាល់គ្នា ហ៊ានប្លន់តែអ្នកទូក អ្នកដំណើរដែលដើររកស៊ីដាច់ដោយឆ្ងាយពីស្រុកពីភូមិគេ ហើយលើកគ្នាទៅទាំងហ្វូងៗផង ឯខ្លួនខ្ញុំ មិនចេះប្លន់អ្នកដើររកស៊ីដាច់ដោយដូច្នេះទេ ខ្ញុំប្លន់តែអ្នកស្រុក អ្នកនគរ ហើយខ្លួនខ្ញុំហ៊ានដូច្នេះដោយខ្ញុំចេះអាគម កាប់មិនមុត ដុតមិនឆេះ ហើយចេះទាំងអាគម បបមំប្រាំបីដាន សាដាន មហាស្រឡប់ មហាស្រឡាយ នាកយណ៍បែងភាគនាកយណ៍ភាឡា ខ្ញុំចេះអស់មិនសល់ នេះខ្ញុំទើបមកពីប្លន់ស្រុកគេ ៗ ឯអស់ពួកចោរ បានស្ដាប់អាឡេវអួតប្រាប់ពីសិល្បសាស្ត្រ អាគមវិជ្ជាការដូច្នោះហើយ ក៏ចង់រៀន ទើបនិយាយនឹងអាឡេវថា បើដូច្នេះ សូមអ្នកបង្ហាញសិល្បសាស្ត្រដល់យើងរាល់គ្នាផង យើងសូមអ្នកធ្វើជាគ្រូឲ្យបង្ហាញប្រដៅ ហើយនៅធ្វើការរកស៊ីជាមួយគ្នា ៗ អាឡេវថា បើអស់អ្នកចង់រៀន ខ្ញុំក៏បង្ហាញបាន ៗ ប៉ុន្តែ ការរកទីធ្វើពិធីចូលត្រណមនោះក្រណាស់ មានតែរកកោះដាច់ពីស្រុកពីភូមិគេ ហើយនៅកណ្ដាលទន្លេ ឆ្ងាយពីត្រើយនោះទើបធ្វើបាន ហើយអាឡេវនឹងចោរ ក៏នាំគ្នាទៅរកកោះកណ្ដាលសមុទ្រ

បានឃើញកោះមួយមានផ្កាខ្យាប់ល្អ ក៏ឡើងទៅលើកោះនោះ រកមើលទី
កន្លែងសមគួរ ឆ្ងាយពីកន្លែងចតសំពៅ អាឡេវប្រាប់ថា បើអ្នកចង់បេះ
អាគមឲ្យពូកែនោះ ត្រូវស្ដាប់ខ្ញុំ បើខ្ញុំបង្គាប់ឲ្យធ្វើអ្វី ត្រូវធ្វើតាមពាក្យខ្ញុំទាំង
អស់ នោះទើបបានអាគមពូកែផុតធាប់ ឯអស់ចោរទាំងប្រាំរយ ក៏ព្រម
ទទួលធ្វើតាមទាំងអស់ ហើយអាឡេវបង្គាប់ឲ្យធ្វើពេធពិធី មានបាយសី
មានទៀនធូបភ្ញីផ្កា ហើយមានពជវ័តិ ធ័ត្រ ទង់ សង់ជារានថ្នាក់ប្រាំពីរជាន់
ហើយឲ្យជីកកកាយដីខ្សាច់ជាអណ្ដូងជំរៅ ឲ្យមានទឹកល្មមមុជលិចក្បាល
លុះធ្វើស្រេចហើយ វាបង្គាប់ចោរទាំងប្រាំរយនាក់ឲ្យកោរសក់ ឲ្យស្រាត
សំពត់ចេញទាំងអស់គ្នា ហើយវាបញ្ឆោតចោរទាំងប្រាំរយថា វិអាគមនេះ
ដែលនឹងរៀននោះ ត្រូវមុជទឹក ហើយនឹកសូត្រអត់ដង្ហើមនៅក្នុងទឹកបាន
ប្រាំពីរបប់ទើបពូកែ ។ ពួកចោរក៏នាំគ្នាហាត់មុជទឹកសូត្រអាគម ។ ឯ
អាឡេវចុះទៅសំពៅ និយាយខ្សិបប្រាប់ប្រពន្ធឲ្យរៀបខ្លួន ហើយឲ្យទាញ
ពួរយុថ្កាឲ្យខ្ញី វាផ្ដាំប្រពន្ធថា បើអញគេចុះមកពីលើគោក ត្រូវទាញពួរយុថ្កា
ឡើងជាធាប់ ផ្ដាំស្រេចហើយក៏ត្រឡប់ទៅវិញ លុះដល់ព្រលប់យប់ងងិត
វាឲ្យពួកចោរមុជទឹក ហើយបង្គាប់ថា បើមុជត្រូវមុជឲ្យព្រមគ្នា បើងើបត្រូវ

ដើម្បីឲ្យព្រមគ្នា ទើបអាគមពូកែ ។ លុះពួកចោរមុជព្រមគ្នាហើយ អាឡេវក៏រត់ចុះទៅសំពៅ ដកយុថ្កាលាក្តោង ដូនជាខ្យល់ដំនោរមកដល់ អាឡេវបើកក្តោងយោងទាំងសំប៉ានទៅ ពោលចោរទាំងប្រាំយនៅលើកោះនោះ ឯចោរទាំងប្រាំយ ដើបអំពីទឹកឡើង រកមើលអាឡេវមិនឃើញ ក៏សួរគ្នាថាលោកគ្រូយើងទៅណា ហើយនាំគ្នារកក្នុងពេងពិធីមិនឃើញ ទើបចុះទៅមើលឯកំពង់ក៏មិនឃើញ បាត់ទាំងសំពៅ ពួកចោរទាំងប្រាំយក៏ដឹងថាអាឡេវបញ្ឆោតហើយ ទើបនាំគ្នារកឈើឫស្សីធ្វើក្បូនចូន ។

---

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) អាគម ។ ២) អាគមបឋម. . . . . . . . .នាពយណ៍កាឡា: (ប:ថ:ម៉ាំង) ។ ៣) វិជ្ជាការ ។ ៤) សំពៅ ។ ៥) បាយសី ។ ៦) កជវ័តិ ។ ៧) ខ្យល់ដំនោរ ។

## ខ) សំនួរ

១) ពួកចោរដែលស្លុងចិត្តជឿដោយតាមការបញ្ឆោតនៃអាឡេវ តើដោយហេតុអ្វី ?

២) ចោរពោលថា: «នៅធ្វើការរកស៊ីជាមួយគ្នា» តើធ្វើការរកស៊ីបែបណា ?

៣) តាមការណ៍ពិត សំពៅជាទូកមួយមានមាឌប៉ុនប្អូធំជាងទូកថ្ងៃ កាឡេវស្ដាំប្រពន្ធឲ្យទាញពួរទាញយុថ្កា ហើយប្រពន្ធទាញបានដូចបំណងមែន តើយើងគួរជឿឬទេ ?

## គ) អត្ថរសទូទៅ

និទាននេះបានជាគតិពីរយ៉ាងគឺអ្វីខ្លះ ?

---

# ពាលធាល់ប្រាជ្ញ

មានបុរសពីរនាក់ មួយឈ្មោះសៅកែ មួយឈ្មោះពាលោ ។ ចៅពាលោនេះ ចេះតែដើររករៀនសិល្បសាស្ត្រ ចេះហើយគិតរកកលបំហូវទ្រព្យរបស់គេថាជារបស់ឯង រមែងនិយាយឆ្លើយឆ្លងតវ៉ានឹងអ្នកផងទាំងពួង ដោយកលកែពាក្យសំដីឲ្យបានប្រកាន់ចាប់ថ្នាក់ ។

មានមួយថ្ងៃ ចៅសៅកែទៅបាញ់ទុងបានមកកូវ ចៅពាលោ គិតក្នុងចិត្តថា ចៅសៅកែ គាត់នឹងចែកសាច់ទុងអញស៊ីផងទេឬអេះ ថាបើគាត់

ពុំបែកស៊ីផង មែនអញទឹងនាំគាត់បង្កើតជាក្ដីឲ្យត្រូវពិន័យម្ដងនេះឯង ៗ ឯចៅសៅកែ ស្ងួ អាំងសាច់ទុងបានឆ្អិនហើយ ក៏ពុំបានបែកចាយឲ្យទៅចៅពាលោ ឡើយ ទើបចៅពាលោ ទៅប្ដឹងឲ្យគោះហៅចៅសៅកែយកទៅជំនុំជំរះ ៗ ក៏ឯពាក្យចៅ ពាលោ ប្ដឹងចៅក្រមនោះ សារស័ព្ទប្រកាន់ថា កាលឪពុកខ្ញុំកំពុងថ្កាត់ បានផ្ដាំខ្ញុំថា បើអញស្លាប់ទៅ សឹងទៅយកកំណើតកើតជាទុង ដោយបំបួរមេបារៀងៗមក ស្លាប់ទៅយកកំណើតជាទុងនោះឯង ល្គឹកបើនរណាគេបាញ់ទុង ឲ្យប្ដឹងចៅក្រមសុំឲ្យចាប់យកមកជំនុំពិចារណាលក់ពិន័យតាមព្រះច្បាប់ ឥឡូវនេះ ចៅសៅកែ សម្លាប់ឪពុកខ្ញុំស៊ីតាមតែចិត្តបំណង់ ហេតុនេះសូមទានប្របាទម្ចាស់ជំរះកាត់សេចក្ដីនេះឲ្យទានខ្ញុំហោង ៗ

ឯចៅសៅកែសោត ឆ្លើយតបថា ឪពុកម្ដាយខ្ញុំ ស្រដីប្រាប់ខ្ញុំរៀងមកថា មេបាជីដូនជីតាញាតិកា ទាំងប្រាំពីរសន្ដាន បណ្ដាដែលស្លាប់ទៅសឹងទៅយកកំណើតជាត្រីទាំងអស់ ហើយផ្ដាំថែមទៀតថា ក្រែងមានសត្វឯណាប្រកបដោយចិត្តក្លៀវក្លា ទៅចាប់សម្លាប់ត្រីស៊ី ឲ្យខ្ញុំបាចបាញ់សម្លាប់សត្វនោះស៊ីវិញ ៗ បើសត្វនោះមានកូនចៅផៅពណិនៅជា

មនុស្ស ឲ្យប្ដីនៅចៅក្រមចាប់យកមកជំនុំជំរះលក់ពិន័យកូនចៅនោះ ឥឡូវនេះ ទុនមួយហ្វូងនាំគ្នាទៅប្ដូនចាប់ត្រីជាដីដូនជីតា ឪពុកម្ដាយខ្ញុំបាទមកស៊ី ទើបខ្ញុំបាទបាញ់ទុនទាំងនោះសម្លាប់ ៗ ពេលនេះ ចៅពាលោក៏ទទួលពាក្យថា ទុននេះជាឪពុកគាត់ហើយ សូមអស់លោកចៅក្រមជំនុំជំរះទោសចៅពាលោ ឲ្យមានខ្ញុំប្របាទផង ៗ ចៅពាលោឆ្លើយថា បើចៅបាញ់ទុនហ្វូងដែលពុំជាឪពុកនោះ អញទនឹងថាអ្វី តែនេះ ចៅទៅបាញ់ទុននៅវៀងអាយ ដែលជាឪពុកអញ ទើបអញស្រដីប្រកាន់ត្រង់នេះឯង ៗ

ចៅក្រមទទួលពាក្យចោទនឹងពាក្យចម្លើយហើយ ប្រឹក្សាគ្នានឹងកាត់សេចក្ដីពុំបានឡើយ ទើបនាំគូក្ដីទាំងសងខាង ឡើងទៅក្រាបទូលសម្ដេចព្រះមហាក្សត្រាធិរាជ តាមដំណើរជាចំណាំរៀងរាល់ខ្លួន ៗ ព្រះរាជាព្រះអង្គមានព្រះបន្ទូលដណ្ដឹងថា ឯទុនឪពុកចៅនៅវៀងអាយ តើស៊ីអ្វីជាអាហារ ស៊ីក្ដាមខ្យងឬស៊ីត្រី ចៅពាលោទូលថា ទទួលព្រះរាជពានត្រី ព្រះអង្គទ្រង់បញ្ជាក់ថា បើដូច្នេះ ឪពុកចៅពាលោឯង សម្លាប់ត្រីជាឪពុកចៅសៅកែស៊ីមែន ទើបព្រះអង្គកាត់សេចក្ដីនេះឲ្យចៅសៅកែ យកចៅពាលោជាខ្ញុំបំរើ ៗ

បុរសទាំងពីរព្រមទទួលតាមព្រះរាជបង្គាប់រួចស្រេចហើយ ក៏ក្រាបថ្វាយបង្គំលា ឯចៅសៅកែ ក៏នាំចៅពាលោ យកទៅធ្វើជាខ្ញុំអាត្មាហោង ។

---

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) បំហូរ ៗ ២) ពិន័យ ៗ ៣) ថ្កាត់ ៗ ៤) បំបួរមេបា ៗ

## ខ) សំនួរ

១) ចៅពាលោដើររៀនអាគម សិល្បសាស្ត្រ ដើម្បីអ្វី ? – ២) ចៅពាលោដែលប្ដឹងអំពីចៅ សៅកែ តើបានសម្រេចប្រយោជន៍ ដូចបំណងឬទេ ? – ៣) ពាក្យចម្លើយដោះសារបស់ចៅពាលោ តើមានសភាពសមតាមពាក្យចោទរបស់ខ្លួនដែលទម្លាក់ទោសមកលើចៅសៅកែឬទេ ?

## គ) អត្ថរសទូទៅ

បើយើងអាននឹងសង្កេតអត្ថបទនេះឲ្យម៉ត់ចត់ទៅ តើយើងនឹងគាបទាញយកពីអត្ថបទនេះ នូវគតិដូចម្ដេច ?

---

# សេចក្តីកតញ្ញូជាធំ

មានបុរសពីរនាក់ដឹកនាំចំណីអាហារ នូវផ្លែឈើផងទាំងឡាយ ម្នាក់ទៅសងគុណអ្នកជាបុព្វការី ម្នាក់ទៀតទៅធ្វើបុណ្យ មួយបររទេះទៅ មួយបររទេះមក ជួនជួបប្រទះគ្នា ពុំចៀសគ្នាឡើយ ហើយឈប់ឈ្លោះប្រកែកជជែកគ្នាជាយូរនៅទីនោះ លុះត្រាតែខូចខាតចំណីអាហារអស់ដោយជណ្តើមផ្លូវគ្នា ៗ ម៉្លោះហើយក៏នាំគ្នាទៅប្តឹងចៅក្រម ៗ ទីងដំនុំពិចារណាពុំបាន ទើបនាំយកទៅក្រាបទូលសម្តេចព្រះមហាក្សត្រាធិរាជ ដល់ហើយ ចៅក្រមថ្វាយសេចក្តីយ៉ាងខ្លីថា បុរសទាំងពីរនេះវិវាទគ្នា ដោយបររទេះពុំចៀសគ្នា ៗ ទ្រង់ព្រះសណ្តាប់ហើយ ព្រះអង្គមានព្រះបន្ទូលត្រាស់ដណ្តឹងថា ព្រះស្តេងទាំងពីរបររទេះពុំព្រមចៀសគ្នា នេះតើដំណើរសេចក្តីអំពីដើមដូចម្តេច ៗ

ចៅមួយក្រាបទូលថា ទូលព្រះបង្គំជាខ្ញុំបររទេះផ្ទុកចំណីអាហារទីងទៅធ្វើបុណ្យ ទៅប្រទះចៅនេះ ៗ ពុំព្រមចៀសឡើយ ចៅមួយទូលឡើងថា លោកដែលជាបុព្វការី មានគុណានឹងទូលព្រះបង្គំជាខ្ញុំ លោកមានធុរៈជា

ទម្ងន់ ហេតុនេះ ទូលព្រះបង្គំជាខ្ញុំ នឹងនាំបណ្ណាការទៅបំពេញកិច្ចតបស្នង សងគុណលោក ជូនប្រទះនឹងរទេះទៅនេះ បរមកពុំព្រមចៀស ។

ដោយព្រះបញ្ញាមុតថ្លា ព្រះអង្គមានព្រះបន្ទូលកាត់សេចក្ដីថា ត្រូវឲ្យព្រះស្ដេចទៅធ្វើបុណ្យ សងអស់របស់ព្រះស្ដេចទៅសងគុណគេនោះ ព្រោះការធ្វើបុណ្យនោះ ដោយចិត្តសទ្ធាឯង ។ ពុំធ្វើដោយបំណាច់អ្វីឡើយ ឯព្រះស្ដេចទៅសងគុណគេ ដ្បិតកាលខ្លួនមានទុក្ខ គេដោះទុក្ខខ្លួន ឥឡូវនេះ ដល់គេមានទុក្ខវិញ ព្រះស្ដេចនោះនឹងទៅដោះទុក្ខ តបស្នងសងគុណគេវិញហោង ។ ហេតុដ្បិតតែព្រះស្ដេចមួយបររទេះពុំចៀស ទើបព្រះស្ដេចនេះខានទៅសងគុណគេ ។

ព្រះអង្គទ្រង់ព្រះតម្រាស់ដោយប្រការដូច្នេះ បុរសទាំងពីរក៏សុខចិត្ត ហើយក្រាបថ្វាយបង្គំ នាំគ្នាទៅកាន់លំនៅអាត្មាឯងទីទៃ ៗ ។ ព្រះមហាក្សត្រាធិរាជ កាត់សេចក្ដីដូច្នេះនេះ ហៅថាសុគតិគមនំហោង ។

---

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) បុត្តការី ។ ២) វិវាទ ។ ៣) ធុរៈ ។ ៤) បណ្ណាការ ។ ៥) សទ្ធា ។ ៦) សុគតិគមនំ ។ (សុគៈតិ គៈមៈណាំង) ។

## ខ) ផែនការ

*ចូរបែកអត្ថបទនេះជាសង្កាត់ តើមានប៉ុន្មាន? – ក្នុងសង្កាត់នីមួយ ៗ តើពោលអំពីអ្វី?*

## គ) អត្ថរសទូទៅ

*សេចក្ដីកតញ្ញូកតវេទិតា នឹងការធ្វើកុសលផលទាំងពីរនេះ តើណាមានអានិសង្សច្រើន ?*

---

# សេចក្ដីរលឹកគុណ

(បទកាកគតិ)

*អហំយើងខ្ញុំ ក្រុញក្រាបប្រណម្យ ព្រះអង្គឥតធ្ងង*
*កាលកបសន្ទុក ពោធិព្រឹក្សទន្ទង ព្រះអង្គជាច្បង*
*ទូទាំងត្រៃភព ។*
*ស្ដេចផ្ចួចការកេ- ត្រាគ្រាប់ត្រដែត ត្រដើងស្កល់ស្កប់*
*ផុតសត្រូវនិករ អមរសោយសព្វ នាំនាំគ្រាន់គ្រប់*
*ដាក់ដល់និព្វាន ។*

បង្គំព្រះធម៌ ប្រសើរមានពណ៌ ជាសំណាញ់ញាណ
សម្តេចពុទ្ធពង្ស ស្រោចស្រង់សត្វបាន បរិបូណ៌បិតឋាន
សុខសួគ៌ទៀងទាត់ ។

បង្គំសង្ឃសាង សីលសុទ្ធលះលាង បាបបោះបង់បាត់
និរទុក្ខប្រាសចាក លាភលះស្នេហ៍ស្និទ្ធ សេពសោយសម្បត្តិ
សុខសួគ៌សោដ្ឋ ។

អញខ្ញុំត្រេកអរ លុតលើកទសករ ដោមដាក់សិរពេ
ក្រញ្ញក្រាបវន្ទា ទេវគុណោ សត្វសោឡសោ
ទាំងចក្រវាល ។

បង្គំមហាក្សត្រ ថ្លៃមានបុណ្យក្តាត់ ឥស្សូរត្រកាល
គ្រងឥន្ទ្រិយ៍បូ- រីរដ្ឋបរិពារ- ក្សេមក្សាន្តបទបារ
បារមីម្ចាស់ថ្លៃ ។

ខ្ញុំសូមបង្គំ គុណគ្រូឧត្តម ប្រដៅខ្ញុំនៃ
បានបរិបូណ៌ចប់ ក្បួនច្បាប់ប្រពៃ ជាពន្លឺក្រៃ
បទគុណគ្រូគាប់ ។

គុណព្រះមាតា  គុណព្រះបិតា  ដែលខ្ញុំគោរព

ទូលទុកនៅនា  សិរសាសោតសព្ទ  ថ្ងៃនិងគោរព

គុណគម្ពីរ ៗ

សាស្ត្រាហង្សយន្ត

---

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) អហំ (អៈហាំង) ៗ ២) ប្រណម្យ ៗ ៣) ត្រៃកព ៗ ៤) សត្វនិករ ៗ ៥) អមរសាយសព្ទ (អៈម៉) ៗ ៦) ពុទ្ធពង្ស ៗ ៧) សេដ្ឋ ៗ ៨) ទសករ ៗ ៩) សិរោ (សិរោ៉) ៗ ១០) សោឡសោ ៗ ១១) ចក្រវាល ៗ ១២) ឥន្ទ្រីយ៍បូរី ៗ ១៣) គុណគម្ពីរ ៗ

## ខ) សំនួរ

១) អ្នកនិពន្ធគោរពជនណាខ្លះ? — ២) អ្នកនិពន្ធទុកព្រះពុទ្ធជាកេត្រា ព្រោះហេតុអ្វី? — ៣) ទេព្តានិងព្រះមហាក្សត្រ មានគុណដូចម្តេចមកលើអ្នកនិពន្ធ? — ៤) អត្ថបទនេះ សឲ្យយើងយល់ថាអ្នកនិពន្ធជាមនុស្សមានសន្តានបែបណា? — ៥) ការរលឹកគុណមានអត្ថប្រយោជន៍ដល់សាមីជនដូចម្តេច?

## គ) អត្ថសេចក្ដី

អត្ថបទនេះ កាលបើយើងអាន ហើយពិចារណាឲ្យហ្មត់ចត់ទៅ តើនឹងអាចឲ្យជាគតិដល់យើងដូចម្ដេច ?

---

# របៀបក្រងផ្កា

(បទភុជង្គលីលា)

នេះបទប្រាកដចងជា កុជង្គលីលា ដោយដានទំនង ។

ថ្ងៃងកាលទេវីនាងក្រង លួលួះម៉ត់ហ្មង រម្យចបុប្ផា ។

នឹងថ្ងៃងសម្ដែងពណ៌នា កាលនាងក្រងផ្កា ក្បូរក្បាច់ច្រើនពេក ។

បុប្ផានានាតំរេក ច្រើនពណ៌អនេក អនន្តណាស់ណា ។

ទេវីក្បត្រីកញ្ញា នាងយកចម្ប៉ា នៃបទនឹងរំដួល ។

នាងក្រងទាំងទងទាំងក្បួរ ជារូបស្រីសួគ៌ សោភសឹងរះរាំ ។

នៃក្រោយយានយ៉ាសចន្ទ្រំ បានបទលំនាំ ទន់ភ្លន់ផ្សាស្រី ។

នាងក្រងកម្រងមួយទី នាងយកមាលតី នៃបទនឹងស្រឡៅ ។

នាងក្រងកម្រងផ្ដេកផ្ដិត ជាបក្សីសត្វ គីហង្សមាសមយ ។

ទំនារុក្ខាព្រឹក្សព្រៃ ហាក់រស់វិស័យ ចឹកចាប់បុប្ផា ៗ

នាងក្រងកម្រងមួយណា នាងយកក្តាំងផា នៃបទឹមហាហង្ស ៗ

នាងក្រងតាំងទង់សោតផ្លូង់ ជារូបរាជហង្ស ហើរពាំភ្ញីមាស ៗ

នាងក្រងផ្កាផងផ្ទុះផ្កាស យករំដេញមាស នៃបទឹងត្រយង់ ៗ

នាងក្រងតាំងទង់សមទ្រង់ ជាក្ងោកពេនពង់ យានយាសរេរា ៗ

នាងក្រងកម្រងមួយណា នាងយកយុថ្កា អញ្ជូនប្បារប្រាល ៗ

នាងក្រងផ្កាផងត្រកាល ជាសេកពេញពាល កាកែរពាំភ្ញី ៗ

នាងក្រងកម្រងមួយនី នាងយកនួនស្រី រីកស្រស់កេសរ ៗ

នាងក្រងកម្រងបវរ ជារូបកិន្នរ ទ្រើសទ្រង់របាំ ៗ

កែក្រាយដជាយរេកំ យានយាសទន្ទាំ ទន្ទេងបានបទ ៗ

នាងក្រងកម្រងប្រាកដ ជារូបស្តេចគ្រុឌ ធៀងឆាបនាគា ៗ

នាងក្រងកម្រងមួយណា សុពណ៌កេត្រា បើកថ្ពងផ្ទុកផ្ងោះ ៗ

នាងក្រងកម្រងមួយនោះ សន្មតនាមឈ្មោះ មាលាសិរស៊ី ៗ

ក្បូរកក្បាច់រំលេចសឹងក្ញី ច្រើនពណ៌ពិសី ពិសេសសោភា ៗ

នាងក្រងផ្កាផងនានា ប្រសើរជាតិជាំ ត្រកាលពេកពន់ ៗ

សាស្ត្រាហង្សយន្ត

## ក) ពន្យល់ពាក្យនិងសំនួនវោហារ

១) បទកុជង្គលីលា ។ ២) បុប្ផា ។ ៣) នានាតិរេក ។ ៤) អនេក ។ ៥) អនន្ត ។ ៦) កែក្រាយ ។ ៧) ផ្កាស្រី ។ ៨) មួយនី ។ ៩) មាសម័យ ។ ១០) សេរីស័យ ។ ១១) យុក្ដា ។ ១២) ត្រកាល ។ ១៣) សុពណ៌កេត្រា ១៤) មាលាសិរសី ។ ១៥) ពិសី ។

## ខ) សំនួរ

១) អ្នកនិពន្ធដែលរិពណ៌នា នូវរបៀបក្រង់ផ្កានេះ បង្ហាញឲ្យយើងឃើញថា ប្រទេសកម្ពុជាសម័យបូរាណ គេចេះសិល្បៈខាងក្រង់ផ្កាបែបណា បើយកមកប្រៀបធៀបនឹងសម័យបច្ចុប្បន្ន?

២) ពាក្យថា «នាងក្រងកម្រងមួយណា» មានន័យដូចម្ដេច? ចូររកឃ្លាណាយមកដាក់ជំនួស ។

## គ) របៀបតែងកាព្យបទកុជង្គលីលា

ចូរពិនិត្យមើលនូវរបៀបតែងកាព្យនេះ តើក្នុងមួយកាព្យមានប៉ុន្មានឃ្លា ហើយឃ្លាទី ១ មានប៉ុន្មានពាក្យ ឃ្លាទី ២ – ឃ្លាទី ៣?

ចូរធ្វើបទកុជង្គលីលាល្បងមើល ព្រោះជាបទកាព្យសម្រាប់លើកទឹកចិត្តឲ្យរីករាយ ហើយចូរបញ្ជាក់ថា តើត្រង់រឿងណា ដែលគេយកបទកុជង្គលីលាមកប្រើ ?

---

## ដំបូន្មានចំពោះធីតា

(បទកាកគតិ)

កាលនោះតាចាស់ ប្រដៅច្បាប់ច្បាស់ ដល់រាជបុត្រី
ឲ្យនាងមានវត្ត ប្រណិប័តន៍នរបតី ស្ដេចជាអគ្គ-
សូរស្វាមីមាន ។

ជាហៃអស់ស្រី នាងទាំងប្រាំពីរ ចូរចាំគ្រប់ប្រាណ
ក្រិត្យនៃច្បាប់ស្រី ពិតពីបូរាណ ពុំដែលឲ្យមាន
ទីទៃឃ្លាតឃ្លា ។

ក្រិត្យមួយកាលផ្ទំ កុំនាងឧត្ដម ចូលមុនរាជា
ក្រិត្យមួយកាលតើន បូរតើនមុនណា កាលសោយសោតស្វា-
មីសោយមុនហោង ។

មួយកាលស្តេចក្រោធ ទ្រគោះពិរោធ ពោលពាក្យគ្គាំគ្គង
កុំនាងតបត ទៅមកឆ្លើយឆ្លង ឲ្យអត់ក្បិណាហោង
ដោយព្រះមាត្រា ។

ទោះគិតអ្វី ៗ ឲ្យព្រហ្មស្វាមី គម្ដែងក្រឡា
កុំដោយចិត្តឯង ពុំក្រែងលោកជា ស្វាមីនោះមហា
ពុំគួរពេកក្រៃ ។

មួយព្រះកូនរ ក្រេវក្រោធទឹងនរ អ្នកណាដទៃ
ចូរមើលឲ្យល្អម ថ្នាក់ថ្នមសូមក័យ អស់អ្នកនោះនៃ
លុះលែងទោសា ។

បរិពារកូនក្រៅ ចូរនាងប្រដៅ កំបាំងក្សត្រា
ឲ្យកាន់ដោយក្រិត្យ បន្ទាត់នោះណា នាងឯងជួយជា
ព្រះនេត្រក្សត្រថ្លៃ ។

អស់បុត្រចង់ចាំ ទទួលបណ្ដាំ ដោយតួទទៃ
គាថិទុកទាន ទុន្មាននោះនៃ ដាក់លើសិរសី
កុំភ្លេចឡើយណា ។

សាស្ត្រាស័ង្ខសិល្បជ័យ

## ក) ពន្យល់ពាក្យនិងសំនួនវោហារ

១) វត្ត ។ ២) មាន (ស្ដូរស្វាមីមាន) ។ ៣) ទីទៃឃ្វាតឃ្វា ។ ៤) ក្រណា ។ ៥) មាត្រា ។ ៦) ព្រហ្មស្វាមី ។ ៧) តម្លៃក្រឡា ។ ៨) កូដរ ។ ៩) អាចិន្ទាទាន ។

## ខ) សំនួរ

១) តាចាស់ គឺជាអ្នកណា? (ឪពុកស្ត្រីទាំងប្រាំពីរនាក់ដែលព្រះករុណាទ្រង់សព្វព្រះទ័យយកធ្វើជាព្រះអគ្គមហេសី) ។ ២) ការប្រណិប័តន៍ចំពោះស្វាមីនៃស្ត្រីក្នុងរឿងនេះ នឹងមានការប៉ះពាល់ដល់សិទ្ធិស្ត្រីសព្វថ្ងៃដែរឬទេ? ៣) ការគោរពស្វាមីក្នុងអត្ថបទនេះ នឹងអាចយកមកអនុវត្តន៍ចំពោះស្ត្រីសាមញ្ញបានឬទេ? – ៤) បើប្ដីខឹង ហេតុអ្វីក៏ឲ្យប្រពន្ធកុំខឹងតប ហើយឲ្យអត់សិន? – ៥) តើគេទុកជាប្រពន្ធបែបណា បើគិតការអ្វីមិនឲ្យប្ដីដឹង? – ៦) សេចក្ដីទូន្មាននៃតាចាស់ ចំពោះកូនស្រីទាំងប្រាំពីរនាក់ មានប៉ុន្មានយ៉ាង? ៧) ត្រង់កាព្យចុងក្រោយបង្អស់ "អស់បុត្រចងចាំ . . . " តើប្រើពាក្យ «បុត្រ» សមនឹងន័យក្នុងអត្ថបទឬទេ? ព្រោះហេតុអ្វី?

# មេមត់មើលជម្ងឺ

(បទពំនោល)

កាលត្រឡប់មកពីនគរកម្ពុជាវិញ នាងកេសរមណ្ឌារធ្វើជាឆ្កួត ព្រោះបាត់ស័ង្ខសិល្បជ័យជាប្ដី ពុំឃើញមក ដោយព្រះកាគិនេយ្យទាំងប្រាំមួយបានរុញទម្លាក់ទៅក្នុងជ្រោះ ។

---

កាលនោះព្រះវរបិតា មានព្រះអាជ្ញា ឲ្យរកមេមត់ពេទ្យផង ។
ក្សិណអស់អាមាត្យអឹងកង រូតរត់ទៅហោង ដូចដោយនូវព្រះអាជ្ញា ។
លុះដល់មេមត់នោះណា៎ បញ្ចាន់មុំមា ឲ្យមើលជម្ងឺស្រីថ្លៃ ។
មេមត់ចុះមើលជើងដៃ ហើយទាយវិងវៃ នារីទាំងពីរក្សត្រី ។
ត្រូវខ្មោចនៅនាគិរី លុះឲ្យគេធី ត្រូវទឹងបំណឺគេផង ។
ទើបស្រោកព្រះជម្ងឺហោង ធ្វើតែបែងផង តែរន្ធតពេកយរវេទនា ។
តែហុំហើយញាំសាក្វា ហៅមហាពិសា ប្រទូចនូវជមគ្រប់គ្រាន់ ។
ហើយដាក់សាច់ទាសាច់មាន់ សាច់ជ្រូកសាច់ក្ដាន់ នូវសាច់ទន្សាយសោតហោង ។
កាលនោះក្មាក់ងារអឹងកង រកដូចបំណង នៃពេទ្យមេមត់បង្គាប់ ។
ខ្ទះកាន់ស្គរប៉ុកយក្រាប់ បន្ទូងសស្រាប់ រំពេចពុំមានខានខាត ។
មេមត់សែនព្រេនដោយខ្នាត លៀនលោមជាអាទិ ហើយហៅព្រលឹងស្រីថ្លៃ ។

មេមត់ចូលទៅចងដៃ នាងនាថស្រីថ្លៃ ទាំងពីរព្រះអង្គក្សត្រី ។
នាងខ្វាល់ថាអញឈឺអ្វី យកអស់គ្នាគ្នី មកមើលដូច្នេះតើគាប់ ។
នាងធាក់មេមត់ស្មើរស្លាប់ ដួលផ្ការដួលផ្កាប់ រលះរលាំងរត់ចេញ ។
ក្សិណោយកពេទ្យចូលមកវិញ ឲ្យបបេណ្ដញ លាពបន់បូជាព្រះគ្រោះ ។
នាងខ្វាល់នាងជេរនាងស្ដោះ ហើយនាងធាក់ត្ពោះ លើក្បាលនៃពេទ្យអប្រិយ៍ ។
នាងថាតើអញឈឺអ្វី កំព្រះនរបតី ឲ្យមើលដូច្នេះតើត្រូវ ។
អស់ពេទ្យមេមត់ខុសត្រូវ ថាយើងឥឡូវ នឹងមើលពុំបានឡើយណា៎ ។
ឲ្យរកទៀតមើលទើបជា ខ្មោចព្រាយមាយា រារឹងបឹងពេកពន់ ។
មើលទៅមិនត្រូវសែកមន្ត មិនមានអាក់អន់ រង្វួតប្រក្លួតកានកាន ។
អ្នកផងចូលទូលក្សត្រក្សាន្ត ឲ្យក្សត្រប្រធាន ឲ្យរើសរកពេទ្យមេមត់ ។
ស្រេចស្រាលអម្បាលជាធុត លែងលោមបានបទ ឲ្យចូលមើលទៀតសោតហោង ។
អស់ពេទ្យមេមត់នេះផង សឹងអួតថ្នាំបង ថ្នាំលាបទូវថ្នាំផឹកផី ។
លុះចូលមើលរាជទេវី សឹងពុំរួចពី ជំណាំនៃនាងធ្វើទុក ។
មេមត់រាងអស់ទាំងស្រុក អាស្រូវអាក្រក់ ទាំងពេទ្យពុំហ៊ានមើលណា៎ ។

សាស្ត្រាស័ង្ខសិល្បជ័យ

---

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) កាតិនេយ្យ ។ ២) មេមត់ ។ ៣) ដូចដោយនូវព្រះអាជ្ញា ។ ៤) តែ ។ ៥) ឲ្យបរបណ្ដេញ ។ ៦) លាពចន៍បូជាព្រះគ្រោះ ។ ៧) រឹងរូតប្រកួតពានការ ៨) ស្រើបស្រាលអម្បាលជាធុត ។ ៩) លែងលោមបានបទ ។

## ខ) សំនួរ

១) ព្រះនាងទាំងពីរអង្គ គឺនរណា? – ២) មេមត់ដែលត្រូវនាងកេសរមណ្ឌារ ធាក់នោះ តើដឹងថាខ្លួននិយាយកុហកឬទេ? – ៣) ដែលថាឲ្យពេទ្យចូលមកមើលម្ដង តើពេទ្យថែបណា? – ៤) ដែលពួកមេមត់នឹងពេទ្យនាំគ្នាពោលថាមាន «ខ្មោចព្រាយមាយា» នៅក្នុងរូបនាងកេសរមណ្ឌារ តើជាការណ៍ពិតឬ?

## គ) អត្ថសេចក្ដីទៅ

រឿងនេះ មានគតិដល់អ្នកអានដូចម្ដេច?

## ឃ) និពន្ធសេចក្ដី

ក) ចូរពិពណ៌នា អំពីការថែអកគា ។

ខ) ចូរពិពណ៌នា អំពីពិធីបញ្ចាន់មេមត់ ។

# ដំបូន្មានស័ក្តសិល្បជ័យ

(បទកាកគតិ)

ទើបមហាក្សត្រក្សាន្ត ឲ្យទុកទាន ដល់រាជកុមារ
ជាហៃកូនរតន៍ ពិចិត្រស្នេហា ប្រាគ្រងកពការ
ពំនាក់ពស្ត្រផង ។

កូនអើយធម្មតា ហៅមហាក្សត្រា ពិកក្តិពស្ត្គផង
លោកឲ្យធ្វើក្រិត្យ ប្រព្រឹត្តធមិផង តាមដោយគន្ធង
ត្រង់ព្រឹទ្ធបុរាណ ។

ឲ្យស្គាល់បាបបុណ្យ ស្គាល់ទោសស្គាល់គុណ ស្គាល់អត់ស្គាល់ឃ្លាន
ស្គាល់ដែនស្គាល់ដី ស្គាល់ទីស្គាល់ស្ថាន ស្គាល់មានស្គាល់គ្មាន
ប្រណីសត្វសាយ ។

កុំអរលោកលន់ កុំពានអានីបុណ្យ បំពូនពាយផាយ
កុំយកដោយធមិ សម្មាពណ្ណពយ បំណោរទៅឆ្ងាយ
ទល់ទុក្ខកយា ។

កូនអើយរែក្សត្រ សោយរាជសម្បត្តិ នោះលោកទបមាំ

ដូចទឹកនេះហោង　បើគ្រនរក្សា　សំបកដូនជា

ឯក្រៅនោះហើយ ៗ

ដូនល្អនលាង　គង់គាប់ថាជា　ឥតមន្ទិលឡើយ

បើគង់នលាង　ដូនជាកូនអើយ　ល្អសាប់ជាត្រើយ

ពុំមានសៅហ្មង ៗ

កាលបើល្អសាប់　ដូនដូច្នោះស្រេច　ល្អទាំងទឹកផង

ដាលដល់កំពីង　បែកផ្សេងគន្លង　ដុះដូចបំណង

កើតផលប្រពៃ ៗ

នរណាឯងជា　សំបកនោះណា៎　និត្យនៅវិស័យ

គឺពស្ត្រប្រជា　សេនាផងនៃ　និត្យនៅក្រៅក្រៃ

ជាសំបកបាន ៗ

រីឯនលាង　នោះតើនរណា　ថាគឺទាហាន

តែងការរស់ព្យូហ៍　សត្រូវសព្វស្ថាន　នាំបាបពុំបាន

នគរឡើយណា៎ ៗ

នរណាជាសាច់　ដូនសោតដោយកិច្ច　គឺស្រមណ៍ក័ក្តុណា៎

អាចារ្យគរី ព្រឹទ្ធឺហោរា នោះហោងហៅថា
សាច់ដូងនោះនៃ ។
នរណាជាទឹក ពិសេសពន្ទឹក គឺមហាក្សត្រថ្លៃ
ឯងជាទឹកពិត ពិនិត្យក្រាស់ក្រៃ តួស្ងួនហាឫទ័យ
ទឹកនោះឯងហោង ។
ទឹកគឺក្សត្រា បើស្ងួនទឹកជា កើតផលកន្ទង
ល្អិតបែកសំបក រកទឹកគ្មានផង បំណោរសោតហោង
សាច់សឹងពុំគាប់ ។
កូនអើយបាបេះ បាចាំអស់នេះ ទំនៀមជាច្បាប់
ព្រេងព្រឹទ្ធអតីតា ទុកជាសម្រាប់ យឺតយូរគួរគាប់
អស់កាលដ៏លន់ ។

សាស្ត្រាសង្ខសិល្បជ័យ

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) សម្មាតណ្ណពយ ។ ២) មន្ទិល ។ ៣) ត្បូហ៍ ។ ៤) នាំបាបពុំបាន ។ ៥) ស្រមណ៍កិត្តុណាំ ។ ៦) ព្រេងព្រឹទ្ធអតីតា ។ ៧) អស់កាលដ៏លន់ ។

## ខ) សំនួរ

១) ស័ន្ធសិល្បជ័យ ទ្រង់ប្រទានព្រះឱវាទដូច្នេះដល់ព្រះរាជកុមារ ដើម្បីប្រយោជន៍អ្វី ?

២) ដូចម្ដេចបានជាស័ន្ធសិល្បជ័យទុកនលាដ៍ដូនដូចជាកន់ទ័ព ?

៣) ដំបូន្មានក្នុងអត្ថបទនេះ នឹងអាចយកទៅអនុវត្តចំពោះនាម៉ឺនសព្វមុខមន្ត្រីផងទាំងពួងបានឬទេ ?

៤) ប្រសិនជាបាន តើព្រោះហេតុអ្វី ?

---

# ដំបូន្មាននៃមេត្រី

(បទព្រហ្មគីតិ)

មេត្រីហែលទៅជាប់ផុច ។ ខាងក្រោយការអង្វរករចំពោះផុច សុំឲ្យមេត្តាដោះលែងអាត្មាតែឥតអំពើ មេត្រី ដោយអស់សង្ឃឹមនឹងមានជីវិតតទៅទៀត ក៏ហៅកូនមកផ្ដុំឲ្យដំបូន្មាន ដូចខាងក្រោមនេះ ៖

---

កូនអើយម្ដាយផ្ដែផ្ដាំ ចូរបងចាំទុកទំនែ
ចាំណាអ្នកមាសថ្លៃ កុំប្រហែសប្រយ័ត្នអង្គ ។

កូនបង្សែងធំបន្តិច នាងបីបាច់រក្សាគ្រង

អាសូរប្រណីផង ប្អូននៅតូចកុំយកទោស ៗ

ប្អូនខុសប៉ុន្មានក្ដី បូរប្រណីផ្ទើសន្ដោស

កុំអ្នកចាំបង់ទោស តបតនឹងប្អូនឡើយណា៎ ៗ

ថាបើបានបំណី ភោជនអ្វីបរិភោគ

រកហៅប្អូនគ្រប់គ្នា មកជួបជុំនាំគ្នាធី ៗ

កុំពោលពាក្យទ្រគោះ កុំនាំឈ្លោះនឹងប្អូនខ្ចី

ប្អូនពុំទាន់ដឹងក្ដី នៅតូចណាស់ណា៎មាសម្ដាយ ៗ

បើកូននឹងនាំគ្នា បរយាត្រាលេងសប្បាយ

រតធីវាលសារាយ កំពឹងពួយត្រួយយាបូង ៗ

បូរកូនកុំប្រហែស នាងកុំធ្វេសដើរដោយជន

បឹងបួរអូរជ្រលង មៀងមើលមុខក្រោយឲ្យច្បាស់ ៗ

ក្រែងពានលើលបលាយ មនុស្សគេពាយមងចាំស្ទាក់

---

ក្រែងគេស្រោស់ជុបដាក់ លបស្រយឹននោះឯងនៅ ៗ

បូរនាងមើលប្រិតប្រៀង មើលឲ្យទៀងរួចសឹមទៅ

បើមានមន្ទិលគួរ　　នឹងក្នែកហើយរាំងបៀសចេញ ។
កុំខំដើរពានពារ　　ទៅលើរាំណាកូនអើយ
ក្រែងបានដៃរាំហើយ　　រាំនឹងលែងឯងកាលណា ។
ខ្វះរាំធ្វើជាថ្នង　　ផ្ទុកអញ្ចុងជនបៃក៏
សំណាញ់សន្ទូចរាំ　　ដឹកទន់ទាញនាំយកទៅ ។

សាស្ត្រាល្បើកដុប

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ចូរចង់ចាំទុកទីទៃ ។ ២) គោជន ។ ៣) ធី ។ ៤) លាយ ។ ៥) ជុច ។ ៦) ស្រយឺនុ ។ ៧) រាំនឹងលែងឯងកាលណា ។ ៨) ជន ។ ៩) បៃក៏ ។ ១០) ផ្ទុក ។

## ខ) ផែនការ

ក្នុងអត្ថបទនេះ មានប៉ុន្មានសង្កាត់? ក្នុងសង្កាត់នីមួយៗ គេពោលអំពីអ្វី?

## គ) សំនួរ

១) សេចក្ដីស្នេហារាំងបង់ថ្នូន ជាហេតុឲ្យជួនលទ្ធផលល្អដូចម្ដេច? —

២) ការប្រៀនប្រដៅនៃមេត្រី ដែលហាមមិនឲ្យកូនហែលទៅជិតនេសា-ទុបករណ៍ទាំងឡាយនេះ តើខ្លាចមានហេតុដូចម្តេច? — ៣) គួរយើងយកសេចក្តីប្រៀនប្រដៅនេះ មកកាឡៃសម្រាប់អនុវត្តចំពោះកុមារទាំងឡាយក្នុងជីវភាពសព្វថ្ងៃបានឬទេ ដូចជាដើរឆ្លងថ្នល់នឹងទីដទៃ?

## ឃ) វេយ្យាករណ៍

១) ចូររកពាក្យជាវេវចនៈ នឹង «បរយាត្រា» — «ក្អែក» ។

២) ចូរពិនិត្យមើលពាក្យ «កុំចំដើរពានពារ ទៅលើវាណាកូនអើយ» តើជាត្រឹមត្រូវឬទេ? ព្រោះហេតុអ្វី?

---

## អកញើសម្លាប់ខ្លួន

(ពាក្យប្រាំពីរ)

ឱកូនកំសត់មាសម្តាយអើយ ម្តេចឡើយបាមកស្លាប់អសារ
ចោលម្តាយឲ្យនៅតែឯកា ម្តាយសូមសច្ចាជួបនឹងអ្នក ។
ម្តាយនឹងរស់នៅតែអង្គឯង ទ្រូងម្តាយចម្បែងតែងអួលអាក់
នឹងរស់នៅថ្វីពុំយល់ភ័ក្ត្រ កូនស្ងួនវរលក្ខណ៍ប្រាសអស់ហើយ ។

នាងអកសោយសោកឱបខ្មោចកូន សន្ធប់សុងសូន្យសោះជាត្រើយ
លុះភ្ញាក់ស្មារតីពុំលង់ឡើយ អកទួញល្ហើយៗតែឯកា ។
ហើយអកកាន់ស្ទាបថ្វាយបង្គំ ប្រណម្យតាំងចិត្តសូមសច្ចា
និងអស់ឥន្ទ្រព្រហ្មទូវទេវតា ទាំងឆកាមាសួគ៌ាល័យ ។
សូមលោកចូលមកជាប្រធាន សាក្សីពេជ្រញាណខ្ញុំនេះនែ
ជាតិនេះខ្ញុំប្រាសកូនមាសម័យ ជាតិក្រោយដទៃកុំឃ្លាតឃ្លា ។
រៀនរូបដរាបដល់និព្វាន បរិបូណ៌ក្សេមក្សាន្តឥតកយា
សច្ចារួចស្រេចឱនវន្ទា ម្នីម្នាទទះស្ទុះផ្លុកផ្លោះ ។
ហើរឡើងទៅលើអាកាសឆ្ងាយ សម្រេចអង្គកាយចុះសំដៅ
ខ្យល់ផាត់អណ្តែតធ្លាក់ស្ទុងស្ទៅ សំដៅកន្ទេនដែលកូនក្ស័យ ។
ស្លាប់ត្រួតតម្រួតគរលើគ្នា ទាំងបីអង្គាមិនគិតខ្នៃ
ព្រោះតែស្នេហ៍ស្និទ្ធគិតអាល័យ ហើយខេរខឹងក្រៃនឹងស្វាមី ។

សាស្រ្តាល្បើកសត្វអក

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ស្លាប់អសារ ។ ២) ម្តាយសូមសច្ចា ។ ៣) លុះភ្ញាក់ស្មារតីពុំលង់

ឡើយ ។ ៤) ផកាមាសខ្លួគាំល័យ ។ ៥) សាក្សីពេជ្រញាណខ្ញុំនេះនៃ ។

៦) កូនមាសម័យ ។

## ខ) សំនួរ

១) កូនអកទាំងអស់ប៉ុន្មាន? – ២) កូនអកស្លាប់ដោយហេតុអ្វី? – ៣) នាងអករន្ធាអ្នកណាខ្លះមុននឹងស្លាប់ខ្លួន? – ៤) នាងអកស្លាប់ដោយហេតុប៉ុន្មានយ៉ាង? – ៥) ការស្លាប់កូនអកនឹងមេអកមានអ្វីជាមូលហេតុ?

## គ) អត្ថរសទូទៅ

កងអត្ថបទនេះ គួរស្រង់យកជាគតិដូចម្តេចខ្លះ?

## ឃ) វេយ្យាករណ៍

១) ចូររកពាក្យជាសមានសព្ទនឹង «មាស» – «សួន» ។

២) ចូរពិនិត្យឃ្លាកាព្យពីរខាងចុង «ហើរឡើងទៅលើអាកាសឆ្ងាយ សម្រុបអង្គកាយចុះសំដៅ . . . . . . » តើមានការត្រឹមត្រូវឬទេ? ព្រោះហេតុអ្វី?

## ង) និពន្ធសេចក្ដី

ចូរអត្ថាធិប្បាយ នូវបុរាណភាសិត "លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា ឆ្កួតក្រៃកន្លង" ហើយសូមនាំយកឧទាហរណ៍មកជាគ្រឿងអាងផង ។

---

## ឆ្កួតបីប្រការ

(បទកាកគតិ)

លោកថាឆ្កួតបី ឆ្កួតមួយនឹងស្រី ឆ្កួតមួយនឹងស្រា
ឆ្កួតមួយនឹងល្បែង អំពើពាលា ឆ្កួតនេះហៅមហា
ឆ្កួតក្រៃកន្លង ។

ឆ្កួតស្រីឆ្កួតស្រា ឆ្កួតល្បែងពាលា អំពើសឹងឆ្គង
លោកពុំឲ្យសេព ឲ្យវៀរជាម្ដង កុំតែងឲ្យហ្មង
ភ្លេចភ្លាំងស្មារតី ។

ឲ្យភ្លេចក្ដីគាប់ ភ្លេចទាំងខ្លួនស្លាប់ ភ្លេចសាសន៍សួស្ដី
ភ្លេចសីលភ្លេចទាន ភ្លេចញាណវុឌ្ឍិ ភ្លេចច្បាប់ប្រក្រតី
ឆ្កួតបីប្រការ ។

កុំអាងចំណោះ　　កុំអួតថាចេះ　　កុំដោយពុតពាល
កុំសមកុំសេព　　កុំស្រើបកុំស្រាល　　កុំអរកុំអាល
　　ត្រេកទៅដោយកា ។

ថាបើនឹងចង់　　សេពដោយចំណាន់　　អំពើពាលា

អាចារ្យលោកចង់　　ជាពាក្យឧបមា　　ឲ្យអ្នកមួយណា
　　ដុតដែកឲ្យក្តៅ ។

បើកាន់ដែកបាន　　នោះទើបឲ្យហ៊ាន　　សេពសមចូលទៅ
អំពើទាំងពី　　ដូចដែកប្រាលផ្អៅ　　លុះកាន់មិនក្តៅ
　　នោះទើបសេពបាន ។

ច្បាប់កូនចៅ

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) លោកពុំឲ្យសេព ។ ២) ក្មេងតាំងស្មារតី ។ ៣) ក្មេងសាសន៍សួស្តី ។ ៤) ក្មេងញាណវុឌ្ឍី ។ ៥) ក្មេងច្បាប់ប្រក្រតី ។

## ខ) សំនួរ

១) ការសេពស្ត្រី ក្រៅពីកិរិយាខ្ជិល-ល្បែង-ស្រា ហេតុម្ដេចក៏ចាត់ទុកជាអំពើឆ្កួត ?

២) ត្រង់ពាក្យថា : «ឲ្យដុតដៃគឲ្យក្ដៅ ហើយឲ្យកាន់ បើកាន់ហើយមិនក្ដៅ ចូរសេពអំពើពាលទាំងបីនេះចុះ» តើអ្នកនិពន្ធមានគោលបំណងយ៉ាងណា ?

---

# ត្រូវចេះសន្សំទ្រព្យ

(បទព្រហ្មគីតិ)

មាសប្រាក់ស្រូវអង្ករ ទុកឲ្យល្អកុំសប្បុរស
សំពៃកុំឲ្យអស់ មើលថៃ្ងជួនខ្វះឯណា ។
ស្បូវស្ដួចកុំឲ្យដាច់ បើរកតិចឲ្យចេះសព្វាហ៍
រិះរកផ្សំទៀតណា ឲ្យបានច្រើនក្រវើនទុក ។
នឹងចាយឲ្យគិតក្រោយ ទោះនឹងឲ្យ ៗ មើលមុខ
កុំឲ្យស៊ីកគ្រលុក ទោះនឹងទុកឲ្យចំណាំ ។
រដូវធ្វើចំការ ឲ្យចេះសព្វាហ៍គ្រឿងគ្រាប់ដាំ

ស្ទឹកគ្រែខ្ញីគ្រប់ត្រុំ ត្រាវត្រសក់សព្វបន្លែ ។

កុំខ្ជិលកុំប្រហួស ទៅផ្ទះរកសុំគេ

គេមិនឲ្យឯងទេ តែគឺមោះព្រោះខ្ជិលដាំ ។

ដោះធ្វើស្រែចំការ ឲ្យឧស្សាហ៍មើលថែទាំ

កុំខ្ជិលកុំប្រចាំ បបបូកដីកស្មៅវល្លិ៍ផង ។

កុំឲ្យបង់កំឡាំង ដោះខំប្រាំងប្រើឲ្យដង

ទឹកទៅស្រោចស្រប់ផង ឲ្យលូតលាស់មានផ្កាផ្លែ ។

ធ្វើការកុំគិតព្រួយ ខ្លួនឯងមួយកុំត្អូញត្អែរ

ខ្លាំងខ្សោយកុំឲ្យល្ហែ ខ្លាចតែនឿយហើយមិនធ្វើ ។

ដាំងយប់បិតបុស្ស ត្បាញជាល្អទៅកញ្ជើ

កុំឲ្យស្រីស្តីលើ ឥតអំពើធ្វើលេងទៅ ។

កុំទុកដៃទទេ ជាងទំនេរបោចស្មៅព្រៅ

ខានផ្ទះខានលំនៅ ឲ្យវាលកាលកើតសុខា ។

ច្បាប់ប្រុស

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) កុំសប្បុរស ៗ ២) កុំស៊ីកគ្រលុក ៗ ៣) ជាន (ជាន់យប់បិតបុស្ស) ៗ

## ខ) សំនួរ

១) ត្រង់ពាក្យថា «កុំឲ្យសប្បុរស» នឹង «កុំឲ្យស៊ីកគ្រលុក» អ្នកនិពន្ធមានបំណងយ៉ាងណា? ចង់ឲ្យជំបូន្មានបែបណា?

២) ត្រង់ពាក្យថា «គេមិនឲ្យឯងទេ» ហេតុម្ដេចក៏អ្នកនិពន្ធពោលជាចំណាត់ជូរចេះ?

៣) «កុំឲ្យស្រីស្ដីលើ» ស្រីក្នុងទីនេះ គឺនរណា?

## គ) ផែនការ

ក្នុងអត្ថបទនេះ មានប៉ុន្មានសង្កាត់? ក្នុងសង្កាត់នីមួយ ៗ គេពោលអំពីអ្វី?

## ឃ) វេយ្យាករណ៍

១) ចូរស្រង់ក្នុងអត្ថបទនេះ នូវពាក្យណាខ្លះដែលក្លាយមកពីបាលីៗ

២) ហេតុអ្វីក៏គេមិនសរសេរ «គ្រលុក» ទៅសរសេរជា "គ្រលុក" វិញ? មិនសរសេរ «កន្ធើ» ទៅសរសេរជា «កញ្ជើ» វិញ?

## ង) និពន្ធសេចក្ដី

ចូរអត្ថាធិប្បាយនូវសុភាសិត «ស្ទូវស្ដួចកុំឲ្យដាច់ បើរ៉ាត់តិចឲ្យ។ សព្វហ៍ រិះរកផ្សំទៀតណា ឲ្យបានច្រើនក្រវើនទុក» មួយអន្ទើនឹង។ ឧទាហរណ៍ជា គ្រឿនអាង ។

---

# ការទៅលើកផុច

(បទបន្ទោរកាក)

តានេះជាម្ចាស់ផុច ដែលមេត្រីហែលទៅចូលជាប់ ហើយដោះខ្លួនមិនរួច ។ លុះព្រឹកឡើង តាគាត់លាប្រពន្ធយ៉ាងប្រញាប់នឹងទៅលើកផុច ខ្លាចក្រែងមានមនុស្សទៅលួចលើកមុន ។

---

នេះនឹងថាថ្ងៃ ឯម្ចាស់ផុចឯងវិញណា
ក្រោកពីនិទ្រា មីមាយកទឹកមកស្ងួន ។
ហើយបែរទៅកេះ អង្រន់ហើយដាស់ប្រពន្ធ
ថាឯងដេកស៊ុន ដល់ថ្ងៃក្រោកឡើងបៀកស្វា ។
បងនឹងទៅព្រៃ នាងតាប់វៃៗមីមា

ក្រែងមានអ្នកណា    ទៅលួចលើកដុចយកត្រី ។
រីឯភរិយា    ក្រោកឡើងប្រវាហាចខ្មី
បៀកស្លាបារី    ដាក់លមហើយស្រេចហុចទៅ ។
ប្ដីទទួលលម    ហើយបែរមកថ្នមប្អូនពៅ
នាងអើយនាងនៅ    នាងដណ្ដាំបាយចាំបង ។
បងមកពីព្រៃ    ក្រែងមានលាភជ័យដូចប៉ង
ស្លធ៏បានម្ដង    ត្រកាលត្រីស្រស់ពិសា ។
ថាតែម៉្លោះហើយ    ពុំបង្អង់ឡើយម្នា
ហូតយកប្រវា    លើដើរចុះទៅកំពង់ ។
ទាញទូកមកស្ដារ    បាចទឹកហើយណាពុំលង់
កាន់ប្រវាប្រុង    ប្រឹងអុំប្រញាប់ទៅហោង ។
ចេញជល់មកវាល    ក្នុងចិត្តត្រអាលឥតហ្មង
ស្រែកច្រៀងរំពង    ដោយចិត្តសប្បាយឥតគ្នេរ ។
ប្អូនអើយបងទៅ    បងទុកប្អូននៅមាសមេ
ឲ្យចាំឲ្យថែ    ផ្ទះឯក្រោយណាឆោមឆាយ ។

បាយ៉ាប់តឿនកឹក លាន់មាត់សើចក្អឹកក្អាកក្អាយ
គ្រែកអរស្រួលសប្បាយ ជាអញមានលាភមែនហោង ។
សមត្រូវត្រីផ្ដោរ ប្តូរមួយត្រីពោព្រាផង
មើលដោយចំនង បាយ៉ាប់តឿននេះមិនទេ ។
ហើយខំអុំទូក លាន់ឮគ្រូកៗគ្មានល្ហែ
តម្រង់ទៅឯ ទីដែលដាក់ដុចនោះនៃ ។

សាស្ត្រាល្បើកដុច

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) និទ្រា ។ ២) ស្ទូន់ (យកទឹកមកស្ទូន់) ។ ៣) លម ។ ៤) ត្រកាល ៥) ពុំលង់ ។ ៦) ចិត្តត្រអាល ។ ៧) ឥតគ្នេរ ។ ៨) បាយ៉ាប់តឿនកឹក ។ ៩) បាយ៉ាប់តឿននេះមិនទេ ។

## ខ) សំនួរ

១) ហេតុអ្វីក៏គាត់ប្រាប់យាយឲ្យបៀកស្ងោយ៉ាងប្រញាប់? – ២) គាត់នឹងយាយជាអ្នកបរិបូណ៌ដោយម្ដេចឬទេ? – ៣) សេចក្ដីត្រង់ណាខ្លះដែលបញ្ជាក់ថាគាត់ជាអ្នកក្រ? – ៤) ហេតុដូចម្ដេចក៏គាត់ស្រែកច្រៀងយ៉ាងសប្បាយ

នៅពេលដែលគាត់អុំទូកទៅលើកដុប? – ៥) តាមការណ៍ពិត ត្រីពោ ទីងត្រីប្រាមានដែលជាប់ដុបឬទេ? – ៦) តាមការសង្កេត ឃើញថាតា មានការផ្លាស់ទឹកចិត្តបីលើក អំពីរឿងទៅលើកដុប តើនៅពេលណាខ្លះ? – ៧) ពាក្យត្រង់ណាខ្លះ សឲ្យឃើញថាតាមានចិត្តស្នេហាយ៉ាងខ្លាំងទៅលើ ប្រពន្ធគាត់?

---

## ភរិយាបួនយ៉ាង

(បទភុជង្គលីលា)

ព្រះពុទ្ធមានបុណ្យគន្លង ទេសនាថែងចង ជាបទគាថា ៗ
មួយមាតុមួយមិត្តភរិយា ភាតុភរិយាជា ទាសភរិយាផង ៗ
ទាំងបួនប្រសើរឥតហ្មង គួរឲ្យចាំចង ទុកក្នុងអង្គា ៗ
រីឯហៅមាតុភរិយា ប្រពន្ធនោះជា លោកទុកស្មើម្តាយ ៗ
ចរិតបីប្រការក្នុងកាយ មួយចង់ខ្វល់ខ្វាយ ប្រយោជន៍ឲ្យប្តី ៗ
បានថ្កើងរុងរឿងឮល្បី មិនឲ្យអាប់ប្តី ឲ្យបានសក្តិយស ៗ

មួយបើប្ដីស្លៀកពាក់ចាស់ យកថ្មីឲ្យផ្លាស់ ចាស់ស្លៀកខ្លួនឯង ៗ
បេះរៀបរណ្ដាប់គាត់តែង ចំណីផងស្វែង រកមកឲ្យប្ដី ៗ
មួយបើប្ដីឈឺថ្កាត់អ្វី ព្រួយប្រឹងមើលប្ដី រកថ្នាំសង្កូវ ៗ
រកពេទ្យមេមត់នូវគ្រូ គ្រោះយាមគន់គូរ មើលប្ដីឲ្យជា ៗ
រីឯហៅភាតុករិយា ប្រសើរសោភា ប្រពន្ធស្មើបង ៗ
នោះមានចរិតពីរផង ដូចប្អូននឹងបង ចិត្តមូលមួយប្រាណ ៗ
មួយធ្វើឲ្យប្ដីគេមកក្លាន្ត របស់ប្ដីបាន បេះទុករក្សា ៗ
មួយនោះឮពាក្យអ្នកណា គេតិះដៀលថា ស្រដីពីប្ដី ៗ
ពុំត្រូវអាស្រូវអប្រិយ បេះការកេរ្ដិ៍ប្ដី បែរបានជាសុខ ៗ
ទោះបីបើប្ដីមានទុក្ខ គិតឲ្យបានសុខ យកខ្លួនជានា ៗ
មួយសោភងមិត្តភរិយា មានចរិតជា បីប្រការមិញ ៗ
បីដូចគល់មិត្តសំឡាញ់ មានចិត្តអស់អញ មិនឲ្យមានហ្មង ៗ
បីដូចគល់ប្អូននឹងបង ប្រាសយូរលង់ហោង ទើបមកជួបគ្នា ៗ
មានចិត្តប្រដិព័ទ្ធមហិមា ដ្បិតបានជួបគ្នា មិនឲ្យមានហ្មង ៗ
មួយមានមារយាទកន្ទួន ទោះឃើញប្រុសផង មិនស្អៀនចិត្តទៅ ៗ

រីទាសភរិយានោះត្រូវ ក្នុងមាត្រាត្រូវ ប្រពន្ធនិប្តី ៗ
ចរិតប្រាំប្រការនី មួយចិត្តខ្លាចប្តី ក្រែងប្តីវាយជេរ ៗ
ប្រុងចិត្តការគិតខ្មាសគេ មិនឲ្យប្តីជេរ បន្ទោសខ្លួនបាន ៗ
ទោះប្តីខឹងក្រៃប៉ុន្មាន មិនចេះហៅហាន ឆ្លើយឈ្លោះតមាត់ ៗ
មួយទោះប្តីនោះគាបក្តាត់ ខឹងដល់វាយវ៉ៃ ជេរបោរជក់ទង ៗ
មិនហ៊ានឆ្លើយឈ្លោះរំលង តតបទៅផង ក្រែងព្រកើ្តទ្វាយ ៗ
មួយចេះប្រដាប់រៀបចាយ ប្តីដើរជិតឆ្ងាយ មិនហ៊ានបរិភោគ ៗ
អត់ចាំទំរាំប្តីមក ជួបជុំទើបយក បរិភោគផងគ្នា ៗ
នេះឯងហៅទាសភរិយា សម្តេចភគវា ទេសនាប្រោសប្រាប់ ៗ
បើអស់ស្រីណាបានស្តាប់ យកទុកជាច្បាប់ ក្នុងប្រាណសព្វថ្ងៃ ៗ
លុះអស់អាយុក្សិណក្ស័យ បានទៅកើតឮ តុសិតសួគ៌នាយ ៗ
នឹងបានគេស្រមក្សាន្តពណ្ណកាយ សេពសុខសប្បាយ និរទុក្ខភយា ៗ

សាស្ត្រាច្បាប់ស្រី

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) ជាបទគាថា ៗ ២) ចរិត ៗ ៣) នូវគ្រូ ៗ ៤) ប្រាណ ៗ ៥) អស់អញ ៗ

៦) ប្រដិព័ទ្ធ ។ ៧) មាត្រា ។ ៨) ជេរបោរដក់ទង ។ ៩) សម្ដេចកគក់ (ក:គ:ក់) ។ ១០) និរទុក្ខកយា ។ ១១) តុសិតសួគ៌ាល័យ ។

## ខ) ផែនការ

ចូរអ្នកពិនិត្យមើល តើអត្ថបទនេះមានប៉ុន្មានសង្កាត់? តើក្នុងសង្កាត់នីមួយៗគេនិយាយពីអ្វី?

## គ) សំនួរ

១) មាតុករិយា មានចរិតបីយ៉ាង គឺអ្វីខ្លះ? ។ ២) ភាតុករិយា? ។ ៣) មិត្តករិយា? ។ ៤) ទាសករិយា? ។ ៥) ចូរពន្យល់បន្តិចមើល: គ្រាន់តែប្រពន្ធគោរពប្រណិប័តន៍ប្ដីដោយត្រឹមត្រូវ មិនដែលបានធ្វើទាន-សីលអ្វីសោះ ហេតុអ្វីក៏អាចឲ្យទៅកើតឋានសួគ៌បាន? ។ ៦) ប្ដីគេទុកជាអ្វីចំពោះប្រពន្ធ?

---

# ត្រូវមានកតញ្ញូតា

(បទកាកគតិ)

កុំធ្វើមាក់ងាយ ទីងគ្រូបាធ្យាយ រៀនចិត្តឲ្យល្អ
ទោះអ្នកឯណា ណែផ្លូវអក្សរ អ្នកនោះឯងអរ
ឲ្យចិត្តមេត្រី ។

កុំឲ្យសៅហ្មង លើលោកកន្លង ពោលពាក្យស្រដី
រឹងរូសទ្រគោះ ឈ្លាសឈ្លោះសេចក្តី កើតទោសអប្រិយ៍
ជេរពោលប្រមាថ ។

អ្នកនោះស្មើគ្រូ បង្កើតអភិរូហ៍ គុណគេឧបាទ
គេជួយប្រដៅ គេហៅឧបាត ដាស់តឿនសង្វាត
ឲ្យឯងចេះឆាប់ ។

បើឯងចេះហើយ កុំភ្លេចគុណឡើយ ឲ្យដឹងដោយប្រាប់
គួរគិតកោតខ្លាច ដើរតាមសណ្តាប់ គន្លងធម៌ប្រាប់
កុំឲ្យមាក់ងាយ ។

នេះឯងគន្លង ត្រឹមត្រូវទំនង អំពើព្រេងនាយ
ឯកពាក្យឥឡូវ ច្រើនតែមាក់ងាយ ចេះហើយជេរម្តាយ
ប្រមាថគ្រូវិញ ។

ហេតុដូច្នោះឯង លោកិយយល់ស្តែង តែងឃើញម្តេចមិញ
ហិនហោចសូន្យសុន លិចលង់ទៅវិញ ទោសនោះឯងមិញ
កើតពីឯណា ? ។

កើតពីចិត្តឯង　បង្កើតស្លះស្លែង　បំផ្លាញអាត្មា
ពេលកាលកង្វោះ　ឆេះកង្វល　បង្កើតទោសា
ឲ្យទុក្ខរូបឯង ។

បេះតែបន្តិច　លើកខ្លួនកំប៉ុច　កំប៉ោងឥតក្រែង
តែងឃើញរៀនមក　យ៉ាងដូច្នោះឯង　ម្ល៉ោះហើយវាតែង
ខុសនឹងទេវតា ។

ច្បាប់អរិយសត្ថា

## ក) ពន្យល់ពាក្យនឹងសំនួនវោហារ

១) កុំធ្វើមាក់ងាយ ។ ២) អ្នកនោះឯងអរ ឲ្យចិត្តមេត្រី ។ ៣) បង្កើតអកិរូហ៍ ។ ៤) គុណគេឧបការ ។

## ខ) សំនួរ

១) អ្នកនិពន្ធប្រដៅថា: «ដើរតាមសណ្ដាប់ គន្លងធម៌ច្បាប់» តើគន្លងធម៌ច្បាប់អ្នកណា ? ។ ២) ដែលអ្នកនិពន្ធពោលថា: «ត្រឹមត្រូវទំនង អំពើព្រេងនាយ» តើអំពើនៃជនណា ? ។ ៣) អ្នកនិពន្ធបានធ្វើសេចក្ដីសង្កេតថា: «ឯកពាក្យឥឡូវ ច្រើនតែមាក់ងាយ បេះហើយដេរម្ដាយ ប្រមាថគ្រូ